
ក្រសួងអប់រំ យុវជន និងកីឡា

សៀវភៅពន្លឿនការសិក្សា

សិក្ខាសង្គម

ថ្នាក់ឆ្នាំទី ៨



សម្រាប់គ្រូបង្រៀន

ព.ស. ២៥៥៨ គ.ស. ២០១៤



ក្រសួងអប់រំ យុវជន និងកីឡា

សៀវភៅពន្យឿនការសិក្សា

សិក្សាសង្គម

ថ្នាក់ឆ្នាំទី ២

ឯកសារសម្រាប់គ្រូ

បោះពុម្ពលើកទី ២
ឆ្នាំ ២០១៥

គណៈកម្មការត្រួតត្រង

ឯកឧត្តម ណាត ប៊ុនរឿន	លោក អ៊ុក សុវណ្ណ
ឯកឧត្តម អ៊ឹម កុច	លោក ចាន់ សុភា
ឯកឧត្តម សំ សេរីរតន៍	លោក ជា វណ្ណេត

គណៈកម្មការនិពន្ធ

លោកស្រី ទូច សុភាព	លោកស្រី ឆាំ ផល្លា
លោកស្រី សាន ណាវ៉ា	លោកស្រី ស៊ូ ណារិន
លោកស្រី ដាន់ សុគន្ធ	លោក ប៊ុន ស៊ីនួន
លោកស្រី អ៊ាវ ណារី	

អ្នករៀបរៀងនិងរចនាចំណារ

លោកស្រី ខ្ងង់ គឹមទូច	លោក អាន រ៉ូប្រាវ

គណៈកម្មការត្រួតពិនិត្យ

លោក ជា វណ្ណេត	លោកស្រី ខ្ងង់ គឹមទូច
លោក អាន រ៉ូប្រាវ	លោកស្រី មិន វិចិត្រា
លោកស្រី ហ៊ុន សុជាតិ	កញ្ញា ធម្ម ស្រីមុំ

បញ្ជីអត្ថបទ

អារម្ភកថា ១
ផ្នែកទី១៖ បំណែងចែកកម្មវិធីសិក្សា ២
ផ្នែកទី២៖ លំនាំនៃការបង្រៀន ៦
ផ្នែកទី៣៖ សលាកប័ត្រជំពូកនិងមេរៀន ១០
ជំពូកទី១ : ការកំណត់គោលដៅ ១១
ជំពូកទី២ : ការកំណត់គោលដៅក្នុងការសិក្សា ១៤
ជំពូកទី៣ : ការស្រឡាញ់រាប់អានគ្នា ១៧
ជំពូកទី៤ : ការយកចិត្តទុកដាក់ចំពោះអ្នកនៅជុំវិញ ២០
ជំពូកទី៥ : ការរក្សាសុវត្ថិភាពក្នុងតំបន់មានមីន ២២
ជំពូកទី៦ : ការចៀសវាងពីការគំរាមកំហែង ២៤
ជំពូកទី៧ : បន្ទាត់ពេលវេលា ២៦
ជំពូកទី៨ : ទីកន្លែងដែលខ្ញុំរស់នៅ ២៨
ជំពូកទី៩ : ប្រទេសកម្ពុជា ៣០
ជំពូកទី១០ : ភាពស្មោះត្រង់ ៣២
ជំពូកទី១១ : សិទ្ធិកុមារ ៣៤
ជំពូកទី១២ : ការបបួលរបស់មិត្តភក្តិ ៣៦
ជំពូកទី១៣ : សុវត្ថិភាពរបស់កុមារនៅពេលជិះកង់ ៣៨
ជំពូកទី១៤ : បុណ្យប្រពៃណីជាតិ ៤១
ជំពូកទី១៥ : តម្លៃការងារ ៤៣
ជំពូកទី១៦ : អំណាចនីតិប្រតិបត្តិ ៤៥
ជំពូកទី១៧ : អាជ្ញាធរដែនដី ៤៧
ជំពូកទី១៨ : ការប្រើប្រាស់ដីនៅតាមតំបន់នានា ៥០
ជំពូកទី១៩ : ដីវិភាពពីសម័យបុរាណ ៥៣

អារម្ភកថា

ឯកសារជំនួយគ្រូមុខវិជ្ជាសិក្សាសង្គម ថ្នាក់ឆ្នាំទី២ នេះ ត្រូវបានរៀបចំឡើងក្រោមកិច្ចសហប្រតិបត្តិការ រវាងក្រសួងអប់រំ យុវជន និងកីឡា ជាមួយនឹងអង្គការ ដើម្បីភាពញញឹមនៃកុមារ នៅក្នុងគម្រោងចងក្រងសៀវភៅពន្លឿនការសិក្សា សម្រាប់សាលាបឋមសិក្សា។ ឯកសារនេះ ត្រូវបានចងក្រងឡើងដោយគណៈកម្មការនិពន្ធក្នុងគម្រោងនេះ និងដោយមានការចូលរួមពីលោកគ្រូអ្នកគ្រូដែលបង្រៀនថ្នាក់ពន្លឿនការសិក្សានៅអង្គការ ដើម្បីភាពញញឹមនៃកុមារ។

ឯកសារនេះ ត្រូវបានបង្កើតឡើងក្នុងគោលបំណងសម្រួលដល់ការបង្រៀនមុខវិជ្ជាសិក្សាសង្គម ថ្នាក់ឆ្នាំទី២ របស់លោកគ្រូអ្នកគ្រូ។ ខ្លឹមសារសំខាន់នៃឯកសារនេះ មានការបង្ហាញពីកម្មវិធីពន្លឿនការសិក្សានៅសាលាបឋមសិក្សា លំនាំនៃការបង្រៀនតាមសមត្ថភាពនីមួយៗ និងសលាកបំត្រជំពូកនិងមេរៀន ពិសេស ផ្តោតទៅលើចម្លើយរបស់សំណួរនិងកំណែលំហាត់ ដែលផ្តល់នូវភាពងាយស្រួល សម្រាប់លោកគ្រូអ្នកគ្រូក្នុងការប្រើប្រាស់សៀវភៅពន្លឿនការសិក្សា។

ក្នុងការបង្រៀន គណៈកម្មការយើងមិនទាមទារ ឱ្យលោកគ្រូអ្នកគ្រូអនុវត្តឯកសារនេះ ទាំងស្រុងនោះទេ។ ប៉ុន្តែកត្តាសំខាន់ គឺជំរុញឱ្យការសិក្សារបស់សិស្សទទួលបានលទ្ធផលល្អប្រពៃ ដោយពឹងផ្អែកលើចំណេះដឹង បទពិសោធ ក្នុងការរៀបចំវិធីបង្រៀន បំណិនប្រសប់ក្នុងការប្រើប្រាស់វាក្យសព្ទ និងសម្ភារឧបទេសក្នុងការបង្រៀនរបស់លោកគ្រូអ្នកគ្រូ។

ក្រោយពីបញ្ចប់មេរៀននីមួយៗ លោកគ្រូអ្នកគ្រូធ្វើរង្វាយតម្លៃលើកម្រិតយល់ដឹងរបស់សិស្ស ដោយធ្វើសំណួរសរសេរ ឬសំណួរផ្ទាល់មាត់ ឬលំហាត់អនុវត្ត ព្រោះវាអាចបង្ហាញឱ្យគ្រូដឹងពីលទ្ធផលបង្រៀន ដើម្បីឱ្យលោកគ្រូអ្នកគ្រូជ្រើសរើសនិងកែសម្រួលវិធីសាស្ត្របង្រៀនឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ថែមទៀត។

គណៈកម្មការនិពន្ធសង្ឃឹមថា ឯកសារជំនួយគ្រូ សិក្សាសង្គម ថ្នាក់ឆ្នាំទី២ នេះ នឹងបានជាប្រយោជន៍ច្រើនដល់ការបង្រៀនរបស់គ្រូ ដើម្បីរួមចំណែកក្នុងការលើកកម្ពស់គុណភាពរៀននិងបង្រៀនប្រកបដោយប្រសិទ្ធភាព។

គណៈកម្មការនិពន្ធ

ផ្នែកទី១
បំណែងចែកកម្មវិធីសិក្សា

កម្មវិធីសិក្សាថ្នាក់ពន្លឿនការសិក្សា មុខវិជ្ជាសិក្សាសង្គម ថ្នាក់ឆ្នាំទី២នេះ គឺជាការសំយោគបញ្ចូលគ្នា រវាងកម្មវិធីសិក្សាមុខវិជ្ជា សិក្សាសង្គម ថ្នាក់ទី៣ និងថ្នាក់ទី៤ នៃកម្មវិធីសិក្សាគោលរបស់ក្រសួងអប់រំ យុវជន និងកីឡា។ មុខវិជ្ជាសិក្សាសង្គម ថ្នាក់ឆ្នាំទី២ នេះ មានចំនួន ២ម៉ោងសិក្សាក្នុង ១សប្តាហ៍ ដែល ១ម៉ោងសិក្សាមានរយៈពេល ៤០នាទី។

ជំពូក	មេរៀន	ចំណងជើងមេរៀន	រយៈពេល
ទី១៖ ការកំណត់គោលដៅ	១	គោលដៅ	១ម៉ោ
	២	គោលដៅទទួលបានជោគជ័យ	១ម៉ោ
	៣	ឧបសគ្គ	១ម៉ោ
	៤	របៀបរៀបចំធ្វើផែនការ	១ម៉ោ
	៥	ការសម្រេចផែនការ	១ម៉ោ
ទី២៖ ការកំណត់គោលដៅក្នុងការសិក្សា	១	ពេលសិក្សានៅក្នុងថ្នាក់	១ម៉ោ
	២	របៀបធ្វើកិច្ចការដើម្បីបានជោគជ័យ	១ម៉ោ
	៣	កត្តារារាំងចំពោះការសិក្សា	១ម៉ោ
	៤	សិក្សាដើម្បីទទួលបានលទ្ធផលល្អ	១ម៉ោ
ទី៣៖ ការស្រឡាញ់រាប់អានគ្នា	១	អំពើល្អរបស់មិត្តខ្ញុំ	១ម៉ោ
	២	យើងត្រូវមានសីលធម៌ល្អក្នុងការរស់នៅ	១ម៉ោ
	៣	យើងត្រូវគោរពច្បាប់មួយចំនួន	១ម៉ោ
ទី៤៖ ការយកចិត្តទុកដាក់ចំពោះអ្នកនៅជុំវិញ	១	មិនយកទ្រព្យសម្បត្តិអ្នកដទៃ	១ម៉ោ
	២	ការថែរក្សាទ្រព្យសម្បត្តិសាធារណៈ	១ម៉ោ
ទី៥៖ ការរក្សាសុវត្ថិភាពក្នុងតំបន់មានមីន	១	គ្រោះថ្នាក់ផ្សេងៗដោយសារមីន	១ម៉ោ
	២	ឥរិយាបថល្អក្នុងតំបន់មានមីន	១ម៉ោ
ទី៦៖ ការចៀសវាងពីការគំរាមកំហែង	១	ល្បិចផ្សេងៗរបស់ជនខិលខូច	១ម៉ោ
	២	វិធីការពារខ្លួនរបស់កុមារ	១ម៉ោ
ទី៧៖ បន្ទាត់ពេលវេលា	១	ដំណើរជីវិតរបស់ដីដូនខ្ញុំ	១ម៉ោ
	២	កាលបរិច្ឆេទសំខាន់ៗនៃដំណើរជីវិតរបស់ដីដូនខ្ញុំ	១ម៉ោ
	៣	ការប្រើប្រាស់បន្ទាត់ពេលវេលា	១ម៉ោ
ទី៨៖ ទីកន្លែងដែលខ្ញុំរស់នៅ	១	គូរទីតាំងនៃកន្លែងសំខាន់ៗក្នុងភូមិ	១ម៉ោ
	២	ទីកន្លែងនិងប្រវត្តិសំណង់អគារចាស់ៗមួយចំនួន	១ម៉ោ
ទី៩៖	១	បទនគរាជ (ចម្រៀងជាតិ)	២ម៉ោ

ប្រទេសកម្ពុជា	២	ទង់ជាតិ	២ម៉ោ
	៣	ប្រទេសកម្ពុជា	១ម៉ោ
ទី១០៖ ភាពស្មោះត្រង់	១	ភាពស្មោះត្រង់របស់យើង	១ម៉ោ
	២	ផលវិបាកនៃភាពមិនស្មោះត្រង់	១ម៉ោ
ទី១១៖ សិទ្ធិកុមារ	១	អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ	១ម៉ោ
	២	សិទ្ធិកុមារ	១ម៉ោ
ទី១២៖ ការបបួលរបស់មិត្តភក្តិ	១	ការបបួលប្រកបដោយប្រយោជន៍សម្រាប់កុមារ	១ម៉ោ
	២	ការបបួលប្រកបដោយគ្រោះថ្នាក់ដល់កុមារ	១ម៉ោ
	៣	វិធីការពារខ្លួន និងការឆ្លើយបដិសេធរបស់កុមារ	១ម៉ោ
ទី១៣៖ សុវត្ថិភាពរបស់កុមារ នៅពេលជិះកង់	១	ឥរិយាបថល្អនៅពេលជិះកង់តាមដងផ្លូវ	២ម៉ោ
	២	សារៈសំខាន់នៃការពាក់មួកសុវត្ថិភាព	១ម៉ោ
	៣	គ្រោះថ្នាក់ផ្សេងៗ	១ម៉ោ
	៤	ផលប្រយោជន៍នៃស្លាកសញ្ញាចរាចរណ៍នៅតាមដងផ្លូវ	១ម៉ោ
	៥	សារៈសំខាន់នៃការគោរពច្បាប់ចរាចរណ៍	១ម៉ោ
ទី១៤៖ បុណ្យប្រពៃណីជាតិ	១	កាលបរិច្ឆេទ និងខ្លឹមសារសំខាន់ៗនៃបុណ្យប្រពៃណីជាតិ	១ម៉ោ
	២	ឥរិយាបថល្អក្នុងពេលចូលរួមពិធីបុណ្យ	១ម៉ោ
ទី១៥៖ តម្លៃការងារ	១	ការងារប្រចាំថ្ងៃរបស់ខ្ញុំ	១ម៉ោ
	២	ផលប្រយោជន៍នៃការធ្វើការងារ	១ម៉ោ
	៣	បំណិនចាំបាច់ក្នុងពេលធ្វើការងារ	១ម៉ោ
ទី១៦៖ អំណាចនីតិប្រតិបត្តិ	១	រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា	៣ម៉ោ
	២	ក្រសួងនានា	១ម៉ោ
ទី១៧៖ អាជ្ញាធរដែនដី	១	អាជ្ញាធរដែនដីរាជធានី.ខេត្ត	១ម៉ោ
	២	អាជ្ញាធរក្រុង.ស្រុក.ខណ្ឌ	១ម៉ោ
	៣	អាជ្ញាធរឃុំ.សង្កាត់	១ម៉ោ
	៤	មេភូមិ	១ម៉ោ
ទី១៨៖ ការប្រើប្រាស់ ដីនៅតាមតំបន់នានា	១	ដីនៅតំបន់បឹងទន្លេសាប	១ម៉ោ
	២	ដីដំណាំបន្ទាប់បន្សំ	១ម៉ោ
	៣	ដីដំណាំឧស្សាហកម្ម	១ម៉ោ
	៤	គួរចម្លងផែនទីប្រទេសកម្ពុជា	២ម៉ោ

ទី១៩៖ ជីវភាពពីសម័យបុរាណ	១	បុរេប្រវត្តិនៃប្រទេកម្ពុជា	២ម៉
	២	សម័យនគរភ្នំ	២ម៉

សរុបម៉ោងក្នុងមួយឆ្នាំសិក្សា

- សរុបម៉ោងទាំងអស់ ២ម៉ × ៣៨សប្តាហ៍ = ៧៦ ម៉ោងសិក្សា
- សរុបម៉ោងបង្រៀន ៦៣ ម៉ោងសិក្សា
- សរុបម៉ោងសល់ ១៣ ម៉ោងសិក្សា

ផ្នែកទី២
លំនាំនៃការបង្រៀន

ផ្អែកតាមលទ្ធផលសិក្សារបស់សិស្ស ប៉ុន្មានឆ្នាំកន្លងមកនេះ យើងឃើញថា សិស្សបឋមសិក្សាមានមូលដ្ឋាននៃការស្រាវជ្រាវនៅមានកម្រិតទាបគួរឱ្យបារម្ភ។ ដើម្បីពង្រឹងគុណភាព នៃការស្រាវជ្រាវឱ្យកាន់តែប្រសើរ ដោយធ្វើការសម្របសម្រួលវិធីសាស្ត្រនិងកែលម្អឯកសារបង្រៀនសិក្សាសង្គម ថ្នាក់ទី៣ និងថ្នាក់ទី៤ របស់ក្រសួងអប់រំ យុវជន និងកីឡា មកជាសៀវភៅពន្លឿនការសិក្សា ថ្នាក់ឆ្នាំទី២ ដើម្បីឱ្យសិស្សក្នុងកម្រិតនេះ ចេះក្នុងទិសដៅឆ្លើយតបទៅនឹងកម្មវិធីពន្លឿនការសិក្សាសម្រាប់កម្រិតសិក្សា ថ្នាក់ឆ្នាំទី២ នេះ ។

ដើម្បីជាជំនួយ ដល់ការប្រើប្រាស់សៀវភៅពន្លឿនការសិក្សានេះ បានត្រឹមត្រូវ គណៈកម្មការបានរៀបចំសេចក្តីណែនាំដោយផ្តោតលើ៖

១. ការប្រើប្រាស់សម្ភារៈ

ក្នុងការបង្រៀនលោកគ្រូ អ្នកគ្រូគប្បីប្រើប្រាស់សម្ភារៈឧបទេស ពីព្រោះវាជាមធ្យោបាយទាក់ទាញអារម្មណ៍សិស្សឱ្យចូលរួមក្នុងការបង្រៀននិងការរៀនយ៉ាងមានប្រសិទ្ធភាព។ ជាពិសេស ធ្វើឱ្យសិស្សងាយចងចាំ សប្បាយរីករាយតាមរយៈការលើកបង្ហាញ ពណ៌នា និងល្បែងសិក្សា។

២. ជំនាំបង្រៀន

មេរៀន: អំពើល្អរបស់មិត្តខ្ញុំ (១ម៉ោង)

សកម្មភាពទី១៖ បញ្ហា

- សួរទំនាក់ទំនង៖ តើទង្វើអ្វីខ្លះដែលគេចាត់ទុកជាអំពើល្អ? ការជួយគ្នា ការរាប់អានគ្នា ការខិតខំរៀនសូត្រ ការជួយធ្វើកិច្ចការផ្ទះ...។
- ដាក់បញ្ហាផ្ទាល់មាត់

  តើអំពើល្អរបស់មិត្តប្អូនពេលរៀនសូត្រ ពេលនៅផ្ទះ នៅទីសាធារណៈមានអ្វីខ្លះ? ចូររៀបរាប់។
- សួរឡើងវិញពីបញ្ហា

- តើអម្ចាញ់មិញគ្រូសួរដូចម្តេច?
- តើប្អូនណាអាចនិយាយឡើងវិញបាន?

- សរសេរ ឬបិទបញ្ហាលើក្តារខៀន

  បញ្ហា៖ តើអំពើល្អរបស់មិត្តប្អូនពេលរៀនសូត្រ ពេលនៅផ្ទះ នៅទីសាធារណៈមានអ្វីខ្លះ? ចូររៀបរាប់។
- សួរកវត្ថុបំណងនៃបញ្ហា តើបញ្ហានេះចង់ឱ្យប្អូនធ្វើអ្វី?
- កែតម្រូវចម្លើយរបស់សិស្ស

សកម្មភាពទី២៖ ការប៉ាន់ស្មាន

- ឱ្យសិស្សប៉ាន់ស្មានដាក់ក្នុងសៀវភៅស្រាវជ្រាវហើយផ្តល់ចម្លើយ
- សរសេរចម្លើយសិស្សដាក់លើក្តារខៀន(នាំបងប្អូនធ្វើការ ចេះប្រើពេលវេលាឱ្យមានប្រយោជន៍ ចេះគោរព និងជួយទុក្ខធុរៈគ្នា។)
- សួរបញ្ជាក់ពីចម្លើយរបស់សិស្ស

  តើប្អូនដឹងថា ការប៉ាន់ស្មានរបស់ប្អូនពិតជាត្រឹមត្រូវឬទេ? បើមិនទាន់ដឹងច្បាស់ទេ តើអ្នកត្រូវធ្វើដូចម្តេចទៀត? (ស្រាវជ្រាវ)

សកម្មភាពទី៣៖ ការស្រាវជ្រាវ

- សួរសិស្ស
- តើអ្នកត្រូវមានអ្វី ដើម្បីស្រាវជ្រាវ? (ឯកសារ)
- តើឯកសារទាំងនោះមានអ្វីខ្លះ? (រូបភាព សៀវភៅ...)
- ឱ្យសិស្សបើកសៀវភៅសិក្សាសង្គមថ្នាក់ឆ្នាំទី២ ទំព័រទី២៣ ដើម្បីស្រាវជ្រាវ។
- ណែនាំរបៀបស្រាវជ្រាវ៖ នៅពេលស្រាវជ្រាវ យើងត្រូវសង្កេត គូររូប កត់ត្រា និងទាញសេចក្តីសន្និដ្ឋានដាក់លើក្រដាសតាមក្រុមរៀងៗខ្លួនៗ ដោយប្រើពេល ១៥នាទី។
- ឱ្យសិស្សនិយាយការណែនាំការស្រាវជ្រាវឡើងវិញឱ្យបាន២ ឬ៣នាក់
- ចែកក្រុមពិភាក្សាដោយមានប្រធានក្រុម លេខាកត់ត្រា និងអ្នកបកស្រាយ
- ដើរពិនិត្យតាមក្រុម ដើម្បីណែនាំបន្ថែមអំពីការខ្វះចន្លោះរបស់សិស្សពេលពិភាក្សាក្រុម

សកម្មភាពទី៤៖ របាយការណ៍ក្រុម

- ឱ្យតំណាងក្រុមនីមួយៗយកកិច្ចការរបស់ខ្លួនមកបិទលើក្តារខៀន
- ឱ្យតំណាងក្រុមឡើងបកស្រាយ
- ឱ្យសិស្សនៃក្រុមដទៃទៀតស្តាប់ការបកស្រាយ បើមានចំណុចណាដែលមិនច្បាស់ ត្រូវសួរ ឯក្រុមបកស្រាយត្រូវឆ្លើយ។ បើសិនជាមិនអាចឆ្លើយបាននោះ សិស្សឯទៀត ឬគ្រូត្រូវចូលរួមបកស្រាយទាល់តែបានច្បាស់។
- សម្របសម្រួលការបកស្រាយ
- ដឹកនាំសិស្សធ្វើការបូកសរុប
- សរសេរការបូកសរុបលើក្តារខៀន

  បូកសរុប៖ អំពើល្អពេលរៀនសូត្រ ពេលនៅផ្ទះ និងនៅទីសាធារណៈ មានដូចជា ជួយពន្យល់មេរៀន នាំបងប្អូនធ្វើការងារ ចេះគោរព និងដឹងទុក្ខធុរៈគ្នា...។

សកម្មភាពទី៥៖ ផ្ទៀងផ្ទាត់ការប៉ាន់ស្មាន

- ឱ្យសិស្សផ្ទៀងផ្ទាត់ចម្លើយទៅនឹងការប៉ាន់ស្មាន៖ តើការប៉ាន់ស្មានរបស់យើងត្រឹមត្រូវឬទេ? បើការប៉ាន់ស្មានដូចនឹងចម្លើយក្នុងការស្រាវជ្រាវ យើងនិយាយថា ការប៉ាន់ស្មានត្រូវបានគាំទ្រដោយការស្រាវជ្រាវ។
- លើកសរសើរសិស្សដែលប៉ាន់ស្មានបានត្រឹមត្រូវ

សកម្មភាពទី៦៖ កសាងមេរៀន

- សួររកពាក្យគន្លឹះ៖ តើប្អូនណាអាចរកពាក្យគន្លឹះនៅក្នុងមេរៀននេះបាន?
- សរសេរពាក្យគន្លឹះលើក្តាខៀន៖ អំពើល្អ ពេលរៀនសូត្រ ពេលនៅផ្ទះ នៅទីសាធារណៈ...។
- ឱ្យសិស្សតែងមេរៀនសង្ខេប៖ តាមរយៈពាក្យគន្លឹះ ចូរប្អូនសាកល្បងតែងជាមេរៀនសង្ខេប ឬគ្រូសួរបំផុសបន្ថែម
- សរសេរមេរៀនសង្ខេបលើក្តារខៀនដោយឱ្យសិស្សថាតាមតៗគ្នារហូតគ្រូសរសេរចប់

មេរៀនសង្ខេប៖ អំពើល្អរបស់មិត្តខ្ញុំមានដូចជា ពេលរៀនសូត្រ គាត់បានជួយពន្យល់មេរៀនឱ្យពួកយើងបានយល់ច្បាស់ ខិតខំរៀនសូត្រ...។ ពេលនៅផ្ទះ គាត់ចេះនាំបងប្អូនធ្វើការងារផ្សេងៗ ចេះប្រើពេលវេលាឱ្យមានប្រយោជន៍។ នៅទីសាធារណៈ គាត់ចេះគោរពនិងដឹងទុក្ខធុរៈគ្នា។

យើងត្រូវយកតម្រាប់តាមអ្នកដែលបានធ្វើអំពើល្អ។ អំពើល្អតែងនាំមកនូវភាពថ្លៃថ្នូរនិងការគោរពរាប់អានពីអ្នកដទៃ។

សកម្មភាពទី៧៖ ការដាក់ចំណងជើង

- សួរកចំណងជើងមេរៀនប្រចាំថ្ងៃ៖ តើថ្ងៃនេះ យើងរៀនអំពីអ្វី? អំពើល្អរបស់មិត្តខ្ញុំ
- សរសេរចំណងជើងលើក្តារខៀន៖ អំពើល្អរបស់មិត្តខ្ញុំ
- ឱ្យសិស្សអានមេរៀនសង្ខេប

ផ្នែកទី៣
សណាគប័ត្រជំពូកនិងមេរៀន

ជំពូកទី១

ការកំណត់គោលដៅ

រយៈពេល	៥ម៉ោង
វត្ថុបំណងមេរៀន	កំណត់គោលដៅប្រកបដោយជោគជ័យក្នុងជីវិតបានត្រឹមត្រូវ។
ចំណងជើងមេរៀន	
មេរៀនទី១	គោលដៅ
មេរៀនទី២	គោលដៅទទួលបានជោគជ័យ
មេរៀនទី៣	ឧបសគ្គ
មេរៀនទី៤	របៀបរៀបចំធ្វើផែនការ
មេរៀនទី៥	ការសម្រេចផែនការ

មេរៀនទី១	**គោលដៅ**
រយៈពេល	១ម៉ោង
វត្ថុបំណង	កំណត់និយមន័យ "គោលដៅ" បានត្រឹមត្រូវ ។
សំភារៈឧបទេស	ស.ស. ទំព័រ២ ដល់ទំព័រ៤ រូបភាព៖ ទំព័រ២-៣-៤
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ៧
ចម្លើយនៃសំណួរ	១. ដែលហៅថាគោលដៅគឺជាចំណុច ឬជាកន្លែងមួយដែលបានកំណត់ទុកជាមុន សម្រាប់ឱ្យមនុស្សធ្វើដំណើរទៅដល់ ឬធ្វើកិច្ចការឱ្យសម្រេចបានលទ្ធផលល្អ។ ២. ខ្ញុំមានគោលដៅ គឺខំរៀនឱ្យបានក្លាយជាសិស្សពូកែនិងសិស្សគំរូ។ ៣. ខ្ញុំមានគោលដៅធ្វើជាគ្រូពេទ្យនៅថ្ងៃអនាគត។
ចម្លើយ/កំណែលំហាត់	**លំហាត់ទី១៖** ក. រៀងរាល់ព្រឹក សុខានិងតារាស្រោចទឹកផ្កា ដើម្បីឱ្យផ្កាលូតលាស់ល្អ។ ខ. នៅពេលទំនេរ គិរី យកក្របីទៅឃ្វាល ដើម្បីជួយការងារឪពុកម្តាយ។ គ. នៅថ្ងៃអាទិត្យ ចិន្តា និងពិសិដ្ឋទៅផ្ទះជីដូនជីតា ដើម្បីសួរសុខទុក្ខគាត់។ **លំហាត់ទី២៖** ក. គ្រូបង្រៀន ខ. គ្រូពេទ្យ (ចម្លើយអាចមានផ្សេងពីនេះ)

មេរៀនទី២	**គោលដៅទទួលបានជោគជ័យ**
រយៈពេល	១ម៉ោង
វត្ថុបំណង	រៀបរាប់ពីកត្តានាំគោលដៅទទួលបានជោគជ័យបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រ៥ ដល់ទំព័រ៦ រូបភាពទំព័រ៥
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ៧
ចម្លើយនៃសំណួរ	១. ដើម្បីឱ្យក្លាយជាអ្នករត់ប្រណាំងទទួលបានជោគជ័យ ខ្ញុំត្រូវកំណត់គោលដៅ ឧស្សាហ៍ ព្យាយាម តស៊ូ និងមានភាពច្បាស់លាស់ក្នុងការអនុវត្តសកម្មភាព។ ២. ដើម្បីអោយបន្ទប់គេងមានសណ្តាប់ធ្នាប់ ខ្ញុំត្រូវរៀបចំទុកជាក់សម្ភារៈក្នុងនោះអោយមានសណ្តាប់ធ្នាប់ល្អជាប្រចាំ។ ៣. ដើម្បីបានរៀនសូត្របន្ត ក្នុងនាមជាកូនកសិករក្រីក្រ ខ្ញុំត្រូវតស៊ូ ព្យាយាម ជម្នះឧបសគ្គក្នុងការធ្វើការងារក៏ដូចជាការរៀនសូត្រ។
ចម្លើយ/កំណែលំហាត់	**លំហាត់ទី១៖** ក. ឧស្សាហ៍ព្យាយាមរៀនសូត្រ **លំហាត់ទី២៖** ក. មានឆន្ទៈ ខ. មានសេក្តីព្យាយាម ឃ. មានភាពច្បាស់លាស់ក្នុងការអនុវត្តសកម្មភាព

មេរៀនទី៣	**ឧបសគ្គ**
រយៈពេល	១ម៉ោង
វត្ថុបំណង	ប្រាប់ពីឧបសគ្គដែលខ្លួនធ្លាប់បានជួបប្រទះក្នុងជីវិតបានត្រឹមត្រូវ ។
សម្ភារឧបទេស	ស.ស. ទំព័រ៧ ដល់ទំព័រ៩ រូបភាពទំព័រទី៥
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ៧
ចម្លើយសំណួរ	១. ដែលហៅថាឧបសគ្គគឺជាហេតុការណ៍ ឬព្រឹត្តិការណ៍ ឬបញ្ហាដែលធ្វើឱ្យគោលដៅមិនបានសម្រេច។ ២. ឧបសគ្គអាចបង្កឡើងដោយសារ កត្តាធម្មជាតិ កត្តាមនុស្ស និងកត្តាសម្ភារៈ។ ៣. ធ្លាប់ជួបឧបសគ្គដូចជាបៃកកង់ គ្រុនក្តៅ ...។ ៤. នៅពេលជួបឧបសគ្គ យើងត្រូវតស៊ូជម្នះឧបសគ្គនោះ។ ៥. ការឈ្នះលើឧបសគ្គ ធ្វើឱ្យយើងក្លាយជាមនុស្សមានកេរ្តិ៍ឈ្មោះល្បីរន្ទឺ។

មេរៀនទី៤	**របៀបរៀបចំធ្វើផែនការ**
រយៈពេល	១ម៉ោង
វត្ថុបំណង	រៀបរាប់ពីរបៀបរៀបចំធ្វើផែនការបានត្រឹមត្រូវ ។
សម្ភារឧបទេស	ស.ស.ទំព័រ១០ ដល់ទំព័រ១១

ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ៧
ចម្លើយនៃសំណួរ	១. ដើម្បីរៀបចំផែនការឱ្យបានជោគជ័យ យើងត្រូវកំណត់ឈ្មោះគោលដៅ កំណត់ពេលវេលាសម្រាប់អនុវត្ត រៀបចំយុទ្ធវិធីជម្នះឧបសគ្គ និងអនុវត្តសកម្មភាពតាមលំដាប់លំដោយ។ ២. បានជាយើងត្រូវរៀបចំផែនការមុននឹងធ្វើសកម្មភាព ដើម្បីឱ្យផែនការនោះ ទទួលបានជោគជ័យ។
ចម្លើយ/កំណែលំហាត់	**លំហាត់៖** ជ្រើសរើសគោលដៅ រួចរៀបចំផែនការ - ការសម្អាតទីធ្លាសាលារៀន (ឈ្មោះគោលដៅ) - ១ព្រឹក ថ្ងៃព្រហស្បតិ៍ (រយៈពេល) - យកសម្ភារៈឱ្យបានគ្រប់គ្រាន់ ពាក់មួកការពារកំដៅថ្ងៃ យកទឹកសម្រាប់ញ៉ាំ (វិធីជម្នះឧបសគ្គ) - អនុវត្តតាមក្រុមទៅតាមទីតាំងនៃក្រុមនីមួយៗ (អនុវត្តសកម្មភាព)

មេរៀនទី៥	**ការសម្រេចផែនការ**
រយៈពេល	១ម៉ោង
វត្ថុបំណង	សម្រេចផែនការដែលបានគ្រោងទុកបានត្រឹមត្រូវ ។
សម្ភារឧបទេស	ស.ស. ទំព័រ១២ ដល់ទំព័រ១៣
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ៧
ចម្លើយ/កំណែលំហាត់	**លំហាត់ទី១៖** បង្ហាញពីការអនុវត្តផែនការ៖ ក. ខ្ញុំមានគោលដៅធ្វើជាសិស្សពូកែម្នាក់។ ខ. ដើម្បីឱ្យគោលដៅនេះបានសម្រេច ខ្ញុំបានធ្វើសកម្មភាពតាមផែនការដែលបានគ្រោងទុក។ គ. សកម្មភាពនោះ អនុវត្តនៅពេលកំពុងរៀន លទ្ធផលគឺក្លាយជាសិស្សដ៏ពូកែម្នាក់។ ឃ. ផែនការបន្តទៀត គឺខ្ញុំត្រូវរៀនបន្តទៅថ្នាក់ឆ្នាំទី៣ ហើយប្រឡងចូលវិទ្យាល័យប្រកបដោយជោគជ័យ។

ជំពូកទី២

ការកំណត់គោលដៅក្នុងការសិក្សា

រយៈពេល	៤ម៉ោ
វត្ថុបំណងមេរៀន	កំណត់គោលដៅក្នុងការសិក្សាបានត្រឹមត្រូវ។
ចំណងជើងមេរៀន	
មេរៀនទី១	ពេលសិក្សានៅក្នុងថ្នាក់
មេរៀនទី២	របៀបធ្វើកិច្ចការដើម្បីបានជោគជ័យ
មេរៀនទី៣	កត្តារារាំងចំពោះការសិក្សា
មេរៀនទី៤	សិក្សាដើម្បីទទួលបានលទ្ធផលល្អ

មេរៀនទី១	**ពេលសិក្សានៅក្នុងថ្នាក់**
រយៈពេល	១ម៉ោង
វត្ថុបំណង	ប្រាប់ពីការកិច្ចពេលសិក្សានៅក្នុងថ្នាក់បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រ១៥ ដល់ទំព័រ១៦ រូបភាពទំព័រទី១៥
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ៧
ចម្លើយនៃសំណួរ	១. សិស្សម្នាក់ៗ ត្រូវសម្អាតថ្នាក់មុននឹងចូលរៀន។ ២. ពេលកំពុងរៀន សិស្សម្នាក់ៗមានតួនាទី រក្សាភាពស្ងៀមស្ងាត់ ស្តាប់គ្រូពន្យល់ និងលើកដៃសួរលោកគ្រូអ្នកគ្រូ នៅពេលដែលមិនយល់ត្រង់ចំណុចណាមួយ។
កំណែលំហាត់	**លំហាត់ទី១៖** ក. ដើម្បីបង្ហាញពីការសិក្សាក្នុងថ្នាក់រៀនបានល្អ យើងត្រូវ៖ - ស្តាប់ការពន្យល់របស់លោកគ្រូ អ្នកគ្រូ - ឆ្លើយនឹងសំណួររប់លោកគ្រូ អ្នកគ្រូ ខ. ឥរិយាបថរបស់សិស្សល្អ - មានកាយវិការឱនលំទោនចំពោះអ្នកគ្រូ **លំហាត់ទី២៖** (១)កុមារ (២)រៀនសូត្រ (៣)ចំណេះដឹង (៤)សិស្សល្អ

មេរៀនទី២	**របៀបធ្វើកិច្ចការដើម្បីបានជោគជ័យ**
រយៈពេល	១ម៉ោង
វត្ថុបំណង	រៀបរាប់ពីរបៀបធ្វើកិច្ចការដើម្បីបានជោគជ័យបានត្រឹមត្រូវ។
សម្ភារៈបង្រៀន	ស.ស.ទំព័រ១៧
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ៧
ចម្លើយនៃសំណួរ	១. ដើម្បីឱ្យការសិក្សាទទួលបានលទ្ធផលល្អ យើងត្រូវចេះពិភាក្សា ជួយគ្នា និងរៀបចំសកម្មភាពតាមលំដាប់លំដោយឱ្យបានត្រឹមត្រូវតាមកិច្ចការនីមួយៗ ២. ខ្ញុំធ្លាប់បានទទួលលទ្ធផលល្អពីការសិក្សា ពីព្រោះខ្ញុំចេះពីរបៀបធ្វើកិច្ចការទាំងនោះដើម្បីបានជោគជ័យ។
កំណែលំហាត់	**លំហាត់ៈ** ក. ស្វ័យសិក្សា គ. សួរគ្រូពេលមានចម្ងល់

មេរៀនទី៣	**កត្តារារាំងចំពោះការសិក្សា**
រយៈពេល	១ម៉ោង
វត្ថុបំណង	រៀបរាប់ពីកត្តារារាំងចំពោះការសិក្សាបានត្រឹមត្រូវ។
សម្ភារៈបង្រៀន	ស.ស. ទំព័រ១៨ ដល់ទំព័រ១៩ រូបភាពទំព័រ១៨
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រទី៧
ចម្លើយនៃសំណួរ	១. កត្តាដែលរារាំងដល់ការសិក្សាបណ្តាលមកពីធម្មជាតិ សុខភាព បរិស្ថាន និងមនុស្ស។ ២. ខ្ញុំអាចជម្នះកត្តាទាំងនោះបាន ដោយខ្ញុំខិតខំថែរក្សាសុខភាពឱ្យបានល្អ បានមករៀនជាប្រចាំ ចូលរួមសម្អាតបរិស្ថានសាលាជារៀងរាល់ថ្ងៃ ដើម្បីឱ្យថ្នាក់រៀនស្អាត គ្មានក្លិនស្អុយ អង្គុយរៀនបានស្រួល និងណែនាំមិត្តភក្តិកុំឱ្យជជែកគ្នាពេលកំពុងរៀនសូត្រ។
កំណែលំហាត់	**លំហាត់ទី១ៈ** ក. ជម្រាបលោកគ្រូ អ្នកគ្រូ ខ. បោសសម្អាតថ្នាក់រៀន **លំហាត់ទី២ៈ** ក. ថ្នាក់រៀនកខ្វក់ រំខានដល់ការរៀនសូត្ររបស់ខ្ញុំ។ ឃ. ទឹកជំនន់ រំខានដល់ការរៀនសូត្ររបស់ខ្ញុំ។

មេរៀនទី៤	**សិក្សាដើម្បីទទួលបានលទ្ធផលល្អ**
រយៈពេល	១ម៉ោង
វត្ថុបំណង	រៀបរាប់ពីកត្តាដែលធ្វើឱ្យការសិក្សាដើម្បីទទួលបានលទ្ធផលល្អបានត្រឹមត្រូវ។

សម្ភារឧបទេស	ស.ស. ទំព័រ២០ ដល់ទំព័រ២១
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ៧
ចម្លើយនៃសំណួរ	ដើម្បីទទួលបានលទ្ធផលល្អក្នុងការសិក្សា - ខិតខំស្តាប់គ្រូពន្យល់ - ចូលរួមធ្វើការងារក្រុម - ក្លាហានសួរ និងឆ្លើយសំណួររបស់គ្រូ។ - ព្យាយាមរៀនសូត្រជាប្រចាំ។ - ជម្នះរាល់ឧបសគ្គផ្សេង ៗ។ - ចេះស្រង់គំនិតសំខាន់ៗ - ចេះបកស្រាយនិងយល់ខ្លឹមសារមេរៀនបានច្បាស់។
កំណែលំហាត់	**លំហាត់ទី១៖** (១)លំហាត់ (២)គោលបំណង (៣)សិស្សពូកែ (៤)សិស្សគំរូ **លំហាត់ទី២៖** ចម្លើយតាមការជាក់ស្តែង

ជំពូកទី៣

ការស្រឡាញ់រាប់អានគ្នា

រយៈពេល	៣ម៉ោ
វត្ថុបំណងមេរៀន	រាប់អានគ្នាបានត្រឹមត្រូវ។
ចំណងជើងមេរៀន	
មេរៀនទី១	អំពើល្អរបស់មិត្តខ្ញុំ
មេរៀនទី២	យើងត្រូវមានសីលធម៌ល្អក្នុងការរស់នៅ
មេរៀនទី៣	យើងត្រូវគោរពច្បាប់មួយចំនួន

មេរៀនទី១	**អំពើល្អរបស់មិត្តខ្ញុំ**
រយៈពេល	១ម៉ោង
វត្ថុបំណង	រៀបរាប់ពីអំពើល្អរបស់មិត្តភក្តិបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី២៣ ដល់ទំព័រទី២៤ រូបភាពទំព័រ២៣
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ៧
ចម្លើយនៃសំណួរ	១. ដែលហៅថាអំពើល្អគឺជាអំពើដែលធ្វើឱ្យអ្នកដទៃពេញចិត្តនិងស្ងើចសរសើរ។ ២. នៅក្នុងថ្នាក់រៀន មិត្តល្អបានជួយខ្ញុំដូចជា ពន្យល់មេរៀន និងលំហាត់ ជួយយកអាសាខ្ញុំ មានអធ្យាស្រ័យចំពោះខ្ញុំ។ នៅផ្ទះចេះនាំបងប្អូនធ្វើការងារ ចេះប្រើពេលវេលាឱ្យមានប្រយោជន៍។ នៅតាមទីសាធារណៈ ចេះគោរពចាស់ទុំ និងដឹងទុក្ខធុរៈគ្នា។ ៣. ការធ្វើអំពើល្អអាចឱ្យយើងបានទទួលផលដូចជា អ្នកដទៃស្រឡាញ់ ចូលចិត្ត និងទទួលបានការសរសើរពីអ្នកដទៃ។ ៤. ខ្ញុំធ្លាប់ទទួលស្គាល់នូវអំពើល្អរបស់អ្នកដទៃដូចជា អ្នកជិតខាងរបស់ខ្ញុំម្នាក់ គឺគាត់ជាអ្នកជំនួញដ៏ធំ ហើយគាត់តែងតែមានចិត្តសប្បុរសជាមួយនឹងអ្នកក្រីក្រ។
កំណែលំហាត់	**លំហាត់៖** ក. នៅពេលជិះរថយន្ត ខ្ញុំនឹងជូនកន្លែងទៅស្ត្រីមានផ្ទៃពោះ និងចាស់ជរា ជនពិការដែលគ្មានកន្លែងអង្គុយ។ ខ. នៅពេលចូលវត្ត ខ្ញុំនឹងដោះមួកនិងរក្សាភាពស្ងៀមស្ងាត់។ គ. ពេលនៅផ្ទះខ្ញុំនឹងជួយធ្វើកិច្ចការផ្ទះ អានសៀវភៅ ធ្វើលំហាត់ដែលអ្នកគ្រូដាក់ឱ្យ និងផ្លៀតពេលជួយបង្រៀនក្មេងៗជិតខាង។

	ឃ. ពេលនៅសាលារៀនខ្ញុំនឹងគោរពវិន័យសាលា ខិតខំរៀនសូត្រ ជួយពន្យល់មេរៀន សិស្សដែលរៀនខ្សោយ និងចូលរួមរាល់សកម្មភាពរបស់សាលា។

មេរៀនទី២	**យើងត្រូវមានសីលធម៌ល្អក្នុងការរស់នៅ**
រយៈពេល	១ម៉ោង
វត្ថុបំណង	ប្រើប្រាស់សីលធម៌ក្នុងការរស់នៅបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី២៥ ដល់ទំព័រទី២៦ រូបភាព៖ ២៥-២៦
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ៧
ចម្លើយនៃសំណួរ	១. សីលធម៌ល្អក្នុងការរស់នៅគឺការគោរពមាតាបិតា លោកគ្រូអ្នកគ្រូ វិន័យសាលាការ ជួយគ្នាក្នុងគ្រាមានអាសន្ន គោរពច្បាប់....។ ២. ដើម្បីឱ្យគ្រួសារមានសុភមង្គល យើងត្រូវចេះគោរព ស្រឡាញ់គ្នា និងជួយធ្វើកិច្ចការ គ្នាទៅវិញទៅមក។ ៣. ខ្ញុំអាចជួយមិត្តភក្តិនៅសាលារៀនដូចជា ជួយពន្យល់មេរៀនគាត់ ជួយពន្យល់ណែនាំ គាត់ឱ្យមានសីលធម៌ល្អ។ ៤. ដើម្បីបង្ហាញថា ខ្ញុំមានសីលធម៌ល្អក្នុងការរស់នៅ គឺត្រូវចេះគោរពចាស់ទុំ ចេះជួយ យកអាសាអ្នកជិតខាងគ្នា...។ ៥. មនុស្សមិនមានសីលធម៌ល្អ ធ្វើឱ្យប្រទេសជាតិជួបផលអាក្រក់ដូចជា ប្រទេសគ្មាន សន្តិភាព គ្មានការរីកចម្រើន កើតភាពចលាចល...។
កំណែលំហាត់	**លំហាត់៖** គេតែងសរសើរយើងហើយរីករាយ ពេលឃើញយើងចេះ៖ ក. ជួយធុរៈអ្នកដទៃ ខ. ជួយពន្យល់មេរៀនមិត្តភក្តិ គ. ជម្រាបសួរចាស់ទុំ ឃ. ជួយយកអាសាអ្នកដទៃ

មេរៀនទី៣	**យើងត្រូវគោរពច្បាប់មួយចំនួន**
រយៈពេល	១ម៉ោង
វត្ថុបំណង	គោរពច្បាប់មួយចំនួនបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី២៧ ដល់ទំព័រទី២៨
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ៧
ចម្លើយនៃសំណួរ	១. យើងត្រូវគោរពច្បាប់ ដើម្បីសេចក្តីសុខ សុវត្ថិភាព និងផលប្រយោជន៍របស់យើងទាំង អស់គ្នា។

	២. បានជាយើងត្រូវការពារព្រៃឈើ ព្រោះព្រៃឈើមានសារៈសំខាន់ខ្លាំងណាស់ដូចជា ទាក់ទាញទឹកភ្លៀង ជាជម្រកសត្វ ជាអាហារសម្រាប់មនុស្ស សត្វ...។ ៣. ការចាក់សំរាមចូលក្នុងប្រភពទឹកនាំមកនូវផលប៉ះពាល់ដូចជា ធ្វើឱ្យទឹកកខ្វក់ បំពុលសត្វក្នុងទឹក ធ្វើឱ្យមនុស្សខូចសុខភាព។
កំណែលំហាត់	**លំហាត់ទី១៖** ខ. បានសុខសប្បាយ **លំហាត់ទី២៖** (១)ធនធាន (២)សម្រាប់ (៣)បំផ្លាញ (៤)អាកាសធាតុ (៥)ប្រើប្រាស់

ជំពូកទី៤

ការយកចិត្តទុកដាក់ចំពោះអ្នកនៅជុំវិញ

រយៈពេល	២ម៉ោ
វត្ថុបំណងមេរៀន	យកចិត្តទុកដាក់ចំពោះអ្នកជិតខាងបានត្រឹមត្រូវ។
ចំណងជើងមេរៀន	
មេរៀនទី១	មិនយកទ្រព្យសម្បត្តិអ្នកដទៃដែលយើងរើសបាន
មេរៀនទី២	ការថែរក្សាទ្រព្យសម្បត្តិសាធារណៈ

មេរៀនទី១	**មិនយកទ្រព្យសម្បត្តិអ្នកដទៃដែលយើងរើសបាន**
រយៈពេល	១ម៉ោង
វត្ថុបំណង	មិនយកទ្រព្យសម្បត្តិអ្នកដទៃដែលយើងរើសបានបានត្រឹមត្រូវ។
សម្ភារៈឧបទេស	ស.ស. ទំព័រទី៣០ ដល់ទំព័រទី៣១
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ៧
ចម្លើយនៃសំណួរ	១. នៅពេលរើសទ្រព្យសម្បត្តិអ្វីមួយរបស់អ្នកដទៃ ខ្ញុំត្រូវយកទៅប្រគល់ឱ្យម្ចាស់គេវិញ។ ២. បានជាយើងមិនយកទ្រព្យសម្បត្តិដែលរើសបាន ព្រោះដើម្បីឱ្យយើងក្លាយជាមនុស្សល្អ។
កំណែលំហាត់	**លំហាត់ទី១៖** ក. សម្លៀត ខ. ប្រគល់ឱ្យម្ចាស់គេវិញ - យកទៅជូនគ្រូដើម្បីសួរកម្ចាស់ **លំហាត់ទី២៖** ក. យើងស្រឡាញ់ទ្រព្យសម្បត្តិរបស់យើង ⇨ គេក៏ស្រឡាញ់ទ្រព្យសម្បត្តិរបស់គេដែរ។ ខ. កាលណាយើងរើសបានសម្ភារៈអ្វីមួយ ⇨ យើងត្រូវយកសម្ភារៈអស់នោះ ប្រគល់ឱ្យម្ចាស់គេវិញ។ គ. យើងស្តាយទ្រព្យសម្បត្តិរបស់យើង ⇨ គេក៏ស្តាយទ្រព្យសម្បត្តិរបស់គេដែរ។

មេរៀនទី២	**ការថែរក្សាទ្រព្យសម្បត្តិសាធារណៈ**
រយៈពេល	១ម៉ោ
វត្ថុបំណង	ចូលរួមថែរក្សាទ្រព្យសម្បត្តិសាធារណៈបានត្រឹមត្រូវ។
សម្ភារៈឧបទេស	ស.ស. ទំព័រទី៣២ ដល់ទំព័រទី៣៣

	រូបភាពទំព័រ៣២
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ៧
ចម្លើយនៃសំណួរ	១. បានជាយើងត្រូវថែរក្សាទ្រព្យសម្បត្តិសាធារណៈ ព្រោះទ្រព្យសម្បត្តិសាធារណៈមានសារប្រយោជន៍សម្រាប់មនុស្សទូទៅ។ ២. ដើម្បីចូលរួមថែរក្សាសាលារៀន យើងត្រូវសម្អាតបរិស្ថានថ្នាក់រៀន មិនលួចទ្រព្យសម្បត្តិរបស់សាលារៀន។
កំណែលំហាត់	**លំហាត់៖** ១. ក គ ឃ ២. ខ

ជំពូកទី៥

ការរក្សាសុវត្ថិភាពក្នុងតំបន់មានមីន

រយៈពេល	២ម៉ោង
វត្ថុបំណងមេរៀន	រក្សាសុវត្ថិភាពនៅតំបន់មានមីនបានត្រឹមត្រូវ។
ចំណងជើងមេរៀន	
មេរៀនទី១	គ្រោះថ្នាក់ផ្សេងៗដោយសារមីន
មេរៀនទី២	ឥរិយាបថល្អក្នុងតំបន់មានមីន

មេរៀនទី១	**គ្រោះថ្នាក់ផ្សេងៗដោយសារមីន**
រយៈពេល	១ម៉ោង
វត្ថុបំណង	រៀបរាប់គ្រោះថ្នាក់ដោយសារមីននិងសញ្ញាសម្គាល់មីនបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី៣៥ ដល់ទំព័រទី៣៦ រូបភាពទំព័រទី៣៥
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ៧
ចម្លើយនៃសំណួរ	១. មីនជាគ្រាប់ផ្ទុះមួយប្រភេទដែលផ្សំឡើងពីសារធាតុគីមីផ្សេងៗដែលអាចបង្កអោយមនុស្សមានគ្រោះថ្នាក់ឬស្លាប់។ ២. សញ្ញាសម្គាល់មីនមានសញ្ញាកួចស្មៅ សញ្ញាឈើខ្វែង សញ្ញាក្បាលខ្មោច។
កំណែលំហាត់	**លំហាត់ទី១៖** ក ខ **លំហាត់ទី២៖**(១)មនុស្ស (២)សត្វ (៣)សញ្ញា (៤)សញ្ញាក្បាលខ្មោច (៥)ព័ត៌មាន (៦)ទីតាំង (៧)រដ្ឋអំណាច

មេរៀនទី២	**ឥរិយាបថល្អក្នុងតំបន់មានមីន**
រយៈពេល	១ម៉ោង
វត្ថុបំណង	ប្រើប្រាស់ឥរិយាបថល្អក្នុងតំបន់មានមីនបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រទី៣៧ ដល់ទំព័រទី៣៨ រូបភាពទំព័រទី៣៧
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ៧
ចម្លើយនៃសំណួរ	១. នៅពេលឃើញមីន ខ្ញុំត្រូវដាក់សញ្ញាសម្គាល់មីន និងរាយការណ៍ជូនរដ្ឋអំណាច។ ២. បើខ្ញុំឃើញនរណាម្នាក់យកសញ្ញាសម្គាល់មីនចេញពីកន្លែងដើម ខ្ញុំត្រូវហាមឃាត់

	និងពន្យល់ប្រាប់គាត់ឱ្យយល់ពីសារប្រយោជន៍នៃសញ្ញាសម្គាល់មីន។
កំណែលំហាត់	**លំហាត់ទី១៖** គ. ជាអំពើដែលធ្វើឱ្យមនុស្សផុតពីគ្រោះថ្នាក់។ **លំហាត់ទី២៖**

ល.រ.	**អំណះអំណាង**	**ត្រឹមត្រូវ**	**មិនត្រឹមត្រូវ**
ក	ផ្លាស់ប្តូរទីតាំងសញ្ញាសម្គាល់មីនលេងផ្តេសផ្តាស		×
ខ	ផ្សព្វផ្សាយដល់អ្នកជំទៃពីកន្លែងដែលមានមីន	✓	
គ	រាយការណ៍ពីកន្លែងមានមីនជូនរដ្ឋអំណាច	✓	
ឃ	បំបាត់សញ្ញាសម្គាល់មីនពីកន្លែងមានមីន		×
ង	បង្កើតសញ្ញាសម្គាល់មីនពេលជួបប្រទះមីន	✓	

ជំពូកទី៦

ការចៀសវាងពីការគំរាមកំហែង

រយៈពេល	២ម៉ោ
វត្ថុបំណងមេរៀន	ចៀសវាងពីការគំរាមកំហែងបានត្រឹមត្រូវ។
ចំណងជើងមេរៀន	
មេរៀនទី១	ល្បិចផ្សេងៗរបស់ជនខិលខូច
មេរៀនទី២	វិធីការពារខ្លួនរបស់កុមារ

មេរៀនទី១	**ល្បិចផ្សេងៗរបស់ជនខិលខូច**
រយៈពេល	១ម៉ោង
វត្ថុបំណង	រៀបរាប់ពីល្បិចផ្សេងៗរបស់ជនខិលខូចបានត្រឹមត្រូវ។
សម្ភារៈបង្រៀន	ស.ស. ទំព័រទី៤០ ដល់ទំព័រទី៤២ រូបភាព៖ ទំព័រទី៤០-៤១
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ៧
ចម្លើយនៃសំណួរ	១. ក្នុងបំណងធ្វើបាបកុមារ ជនខិលខូចមានល្បិចដូចជាឱ្យលុយ ឱ្យចំណីញ៉ាំ ជិះឡាន ដើរលេង ធានាថារកការងារឱ្យធ្វើ...។ ២. ពាក្យសម្តីដែលកុមារគួរប្រើជាមួយជនខិលខូចដូចជា «ទេ! អរគុណច្រើន! ខ្ញុំប្រញាប់ណាស់! លាសិនហើយ!ខ្ញុំមិនយកលុយពូទេ! អរគុណពូ!!ខ្ញុំមាននំញ៉ាំហើយ! ទេពូ!ខ្ញុំមានអ្នកជូនទៅផ្ទះហើយ។»
កំណែលំហាត់	**លំហាត់៖** ជនខិលខូចធ្វើសកម្មភាពបោកបញ្ឆោតទៅលើកុមារដើម្បី៖ ក. ធ្វើជាអាជីវកម្ម ខ. យកទៅធ្វើការងារធ្ងន់ៗ ឃ. យកទៅធ្វើជាជនទុច្ចរិត ដើម្បីរកប្រាក់ឱ្យពួកគេ

មេរៀនទី២	**វិធីការពារខ្លួនរបស់កុមារ**
រយៈពេល	១ម៉ោង
វត្ថុបំណង	រៀបរាប់ពីវិធីការពារខ្លួនរបស់កុមារបានត្រឹមត្រូវ។
សម្ភារៈបង្រៀន	ស.ស. ទំព័រទី៤៣ ដល់ទំព័រទី៤៤

	រូបភាពទំព័រទី៤៣
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ៧
ចម្លើយនៃសំណួរ	១. កាលណាមានបញ្ហាកើតឡើង ខ្ញុំត្រូវស្រែកថា «ទេ» ហើយរត់ទៅរកមិត្តភក្តិ រត់ទៅរកអាជ្ញាធរមានសមត្ថកិច្ចប្រាប់ពីល្បិចជនខិលខូចឱ្យគេដឹង។ ២. បើខ្ញុំលាក់រឿងដែលខ្ញុំបានជួប ខ្ញុំនឹងទទួលផលវិបាកដូចជាស្តាយក្រោយ នៅពេលដែលរឿងនេះវាធ្លាក់ទៅលើកុមារដទៃ រហូតធ្វើឱ្យកុមារទាំងនោះរងគ្រោះថ្នាក់។ ៣. ខ្ញុំមិនគួរដើរលេងឆ្ងាយតែម្នាក់ឯងទេ ព្រោះវាអាចជាឱកាសឱ្យជនខិលខូចធ្វើបាបខ្ញុំ ហើយម្យ៉ាងទៀត ពេលជួបបញ្ហាគ្មានអ្នកណាអាចជួយខ្ញុំបានទេ។ ៤. ខ្ញុំធ្លាប់បានឮគេនិយាយប្រាប់គ្នាពីល្បិចជនខិលខូចដែរ គេនិយាយដូចជាជនខិលខូចឱ្យលុយទៅកុមារ ទិញរបស់របរឱ្យកុមារ នាំកុមារដើរកម្សាន្ត ... បើកុមារមិនដឹងពីកលល្បិចនេះទេ កុមារនឹងធ្លាក់ក្នុងសភាពគ្រោះថ្នាក់។
កំណែលំហាត់	**លំហាត់៖** ខ. ប្រកែក ហើយរត់ទៅរកមិត្តភក្តិ ង. ស្រែក «ទេ» ឱ្យខ្លាំងៗ

ជំពូកទី៧


បន្ទាត់ពេលវេលា

រយៈពេល	៣ម៉ោង
វត្ថុបំណងមេរៀន	ប្រើប្រាស់បន្ទាត់ពេលវេលាបានត្រឹមត្រូវ។
ចំណងជើងមេរៀន	
មេរៀនទី១	ដំណើរជីវិតរបស់ជីដូនខ្ញុំ
មេរៀនទី២	កាលបរិច្ឆេទសំខាន់ៗនៃដំណើរជីវិតរបស់ជីដូនខ្ញុំ
មេរៀនទី៣	ការប្រើប្រាស់បន្ទាត់ពេលវេលា

មេរៀនទី១	**ដំណើរជីវិតរបស់ជីដូនខ្ញុំ**
រយៈពេល	១ម៉ោង
វត្ថុបំណង	រៀបរាប់ពីដំណើរជីវិតរបស់ជីដូនបានត្រឹមត្រូវ ។
សម្ភារឧបទេស	ស.ស.ទំព័រ៤៦ ដល់ទំព័រ៤៧ រូបភាពទំព័រ៤៦
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ៧
ចម្លើយនៃសំណួរ	១. ជីដូនរបស់ខ្ញុំធ្លាប់បានចូលរៀន។ ២. មុនរបបប៉ុលពតគាត់ជាគ្រូបង្រៀន។ ៣. ក្រោយពីរបបប៉ុលពតគាត់ជានាយិកាសាលា។
ចម្លើយ/កំណែលំហាត់	**លំហាត់ទី១៖** (១)កើត (២)ចូលរៀន (៣)បញ្ចប់ (៤)ចូលនិវត្តន៍ **លំហាត់ទី២៖** ចម្លើយតាមការជាក់ស្តែង

មេរៀនទី២	**កាលបរិច្ឆេទសំខាន់ៗនៃដំណើរជីវិតរបស់ជីដូនខ្ញុំ**
រយៈពេល	១ម៉ោង
វត្ថុបំណង	កំណត់កាលបរិច្ឆេទសំខាន់ៗនៃព្រឹត្តិការណ៍ក្នុងដំណើរជីវិតរបស់ជីដូនបានត្រឹមត្រូវ ។
សម្ភារឧបទេស	ស.ស.ទំព័រ៤៨ ដល់ទំព័រ៤៩
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ៧
ចម្លើយនៃសំណួរ	១. ក្រោយឆ្នាំ១៩៧៩ លោកយាយបានរៀបការ។ ២. ចៅរបស់លោកយាយកើតនៅឆ្នាំ ១៩៩៧។ ៣. ចៅរបស់លោកយាយបានចូលលរៀននៅឆ្នាំ ២០០៤។

ចម្លើយ/កំណែលំហាត់	**លំហាត់៖** ក. ឆ្នាំ១៩៩៣ ⇨ សម្តេចនរោត្តមសីហនុឡើងគ្រងរាជ្យជាថ្មី។ ខ. ឆ្នាំ១៩៧០ ⇨ ប្រទេសកម្ពុជាប្តូរពីរបបរាជានិយមទៅជាសាធារណរដ្ឋ។ គ. ឆ្នាំ១៩៧៩ ⇨ រំដោះរួចផុតពីរបបប្រល័យពូជសាសន៍ប៉ុលពត។

មេរៀនទី៣	**ការប្រើប្រាស់បន្ទាត់ពេលវេលា**
រយៈពេល	១ម៉ោង
វត្ថុបំណង	ប្រើប្រាស់បន្ទាត់ពេលបានត្រឹមត្រូវ ។
សម្ភារឧបទេស	ស.ស.ទំព័រ៥០ ដល់ទំព័រ៥១ រូបភាពទំព័រ៥០
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ៧
ចម្លើយនៃសំណួរ	១. បន្ទាត់ពេលវេលាមានដៅបង្ហាញពីពេលវេលានិងព្រឹត្តិការណ៍សំខាន់។ ២. គេប្រើបន្ទាត់ពេលវេលាដើម្បីចងចាំព្រឹត្តិការណ៍ផ្សេងៗ។
ចម្លើយ/កំណែលំហាត់	**លំហាត់ទី១៖** បន្ទាត់ពេលវេលាសំខាន់ៗដើម្បីបង្ហាញពីសកម្មភាព (គិតជាម៉ោង) របស់ខ្ញុំកាលពីម្សិលមិញ។  **លំហាត់ទី២៖** ចម្លើយតាមការជាក់ស្តែង

.

ជំពូកទី៨

ទីកន្លែងដែលខ្ញុំរស់នៅ

រយៈពេល	២ម៉ោង
វត្ថុបំណងមេរៀន	ប្រាប់ពីកន្លែងរបស់ខ្លួនរស់នៅបានត្រឹមត្រូវ។
ចំណងជើងមេរៀន	
មេរៀនទី១	គូរទីតាំងនៃកន្លែងសំខាន់ៗក្នុងភូមិខ្ញុំ
មេរៀនទី២	ទីកន្លែងនិងប្រវត្តិសំណង់អគារចាស់ៗមួយចំនួន

មេរៀនទី១	**គូរទីតាំងនៃកន្លែងសំខាន់ៗក្នុងភូមិខ្ញុំ**
រយៈពេល	១ម៉ោង
វត្ថុបំណង	គូរទីតាំងនៃកន្លែងសំខាន់ៗក្នុងភូមិបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស.ទំព័រ៥៣ ដល់ទំព័រ៥៤ រូបភាពទំព័រ៥៣
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ៧
ចម្លើយនៃសំណួរ	១. ដើម្បីឱ្យគេស្គាល់ផ្ទះ ខ្ញុំត្រូវប្រាប់ឈ្មោះភូមិ ឃុំ.សង្កាត់ ក្រុង.ស្រុក.ខណ្ឌ រាជធានី.ខេត្ត និងទីតាំងកន្លែងសំខាន់ៗសម្រាប់សម្គាល់។ ២. នៅក្នុងភូមិដែលខ្ញុំរស់នៅមានកន្លែងសំខាន់ៗដូចជា វត្ត មន្ទីរពេទ្យ សាលារៀន ផ្សារ សាលាឃុំ... ។ ៣. ដើម្បីឱ្យគេស្គាល់កន្លែងសំខាន់ៗទាំងនោះ ខ្ញុំត្រូវគូរផែនទីបង្ហាញដោយបញ្ជាក់ទីតាំងនៃកន្លែងនីមួយៗនោះ។
ចម្លើយ/កំណែល់ហាត់	**ល់ហាត់ៈ** ចម្លើយតាមការជាក់ស្តែង

មេរៀនទី២	**ទីកន្លែងនិងប្រវត្តិសំណង់អគារចាស់ៗមួយចំនួន**
រយៈពេល	១ម៉ោង
វត្ថុបំណង	រៀបរាប់ពីទីកន្លែងនិងប្រវត្តិសំណង់អគារចាស់មួយចំនួនបានត្រឹមត្រូវ ។
សម្ភារឧបទេស	ស.ស.ទំព័រ៥៥ ដល់ទំព័រ៥៧ រូបភាពទំព័រ៥៥
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ៧
ចម្លើយនៃសំណួរ	១. ដែលហៅថាសំណង់អគារបុរាណគឺជាសំណង់ដែលមានអាយុកាលរាប់រយឆ្នាំណាស់

	មកហើយ។ ២. អគាររដ្ឋសភាចាស់ស្ថិតនៅសង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ ៣. ដំបូងអគាររដ្ឋសភាចាស់ជាបណ្ណាល័យតម្កល់គម្ពីរព្រះត្រៃបិតកនិងសម្បត្តិវប្បធម៌ព្រះពុទ្ធសាសនា។ ៤. បានជាគេនិយមហៅសារមន្ទីរជាតិថា « សាលារចនា » ព្រោះកាលនោះ អគារនេះជាសារមន្ទីរផងនិងជាសាលាបណ្តុះបណ្តាលផង។ ៥. ផ្ទះរោងឱ្យមានលក្ខណៈជាផ្ទះមានដំបូលធំមួយ មានសំយ៉ាបនៅខាងមុខនិងខាងក្រោយសម្រាប់ជាក់ត្បាល់ក្តឿង។ ៦. សំណង់អគារបុរាណមានប្រយោជន៍សម្រាប់ជាទីកន្លែងស្រាវជ្រាវប្រវត្តិសាស្ត្រនិងស្ថាបត្យកម្មបុរាណរបស់ជាតិខ្មែរ។
ចម្លើយ/កំណែលំហាត់	**លំហាត់ទី១៖** ក. ១៩១៧ ខ.១៩១៧ **លំហាត់ទី២៖** សារមន្ទីរជាតិមានសារសំខាន់ដល់ភ្ញៀវជាតិនិងអន្តរជាតិឱ្យយល់ដឹងពីវប្បធម៌ និងបង្ហាញពីកេរដំណែលរបស់ស្ថាបត្យកម្មបុរាណរបស់ជាតិខ្មែរ។

ជំពូកទី៩

ប្រទេសកម្ពុជា

រយៈពេល	៥ម៉ោង
វត្ថុបំណងមេរៀន	ប្រាប់លក្ខណៈទង់ជាតិប្រទេសកម្ពុជាបានត្រឹមត្រូវ។
ចំណងជើងមេរៀន	
មេរៀនទី១	បទនគររាជ
មេរៀនទី២	ទង់ជាតិ
មេរៀនទី៣	ប្រទេសកម្ពុជា

មេរៀនទី១	**បទនគររាជ**
រយៈពេល	២ម៉ោង
វត្ថុបំណង	ច្រៀងចម្រៀងជាតិបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស.ទំព័រ៥៩ ដល់ទំព័រ៦០ រូបភាពទំព័រ៥៩
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ៧
ចម្លើយនៃសំណួរ	១. បទនគររាជជាចម្រៀងជាតិរបស់ប្រទេសខ្មែរ។ ២. គេច្រៀងបទនគររាជនៅពេលគោរពទង់ជាតិ។ ៣. បទនគររាជជាស្នាព្រះហស្តរបស់សម្តេចព្រះសង្ឃរាជ ជួន ណាត។
ចម្លើយ/កំណែលំហាត់	**លំហាត់ទី១៖** ៣វគ្គ **លំហាត់ទី២៖** ដើម្បីលើកកម្ពស់ជាតិរបស់យើង។

មេរៀនទី២	**ទង់ជាតិ**
រយៈពេល	២ម៉ោង
វត្ថុបំណង	រៀបរាប់ពីទ្រង់ទ្រាយនិងអត្ថន័យពណ៌ទង់ជាតិប្រទេសកម្ពុជានិង ប្រទេសជិតខាងបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស.ទំព័រ៦១ ដល់ទំព័រ៦២ រូបភាព៖ ទង់ជាតិប្រទេសកម្ពុជា ឡាវ ថៃ
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ៧

ចម្លើយនៃសំណួរ	១. ទង់ជាតិប្រទេសកម្ពុជាមាន ៣ពណ៌ គឺពណ៌ខៀវ នៅជាយសងខាង និងពណ៌ក្រហមនៅកណ្តាល។ នៅចំកណ្តាលផ្ទៃក្រហមមានរូបប្រាសាទអង្គរវត្តពណ៌ស។ ២. ខ្ញុំស្គាល់ទង់ជាតិប្រទេសឡាវ ថៃ វៀតណាម។ ៣. ពណ៌នៃទង់ជាតិប្រទេសនីមួយៗ • ឡាវមាន ៣ពណ៌ គឺពណ៌ក្រហមនៅជាយសងខាង និងពណ៌ខៀវនៅកណ្តាល។ នៅចំកណ្តាលផ្ទៃពណ៌ខៀវមានរូបព្រះចន្ទពណ៌ស។ • ថៃមាន ៣ពណ៌ គឺឆ្នូតពណ៌ក្រហមនៅជាយសងខាង ឆ្នូតពណ៌ស នៅសងខាងបន្ទាប់ និងឆ្នូតពណ៌ខៀវនៅចំកណ្តាល។ • វៀតណាមមាន ២ពណ៌ គឺផ្ទៃពណ៌ក្រហម និងផ្កាយពណ៌លឿងនៅចំកណ្តាល។
ចម្លើយ/កំណែលំហាត់	**លំហាត់ទី១៖** ក. ភ្លាហាន តស៊ូ ខ. ភាពសច្ចៈ ស្មោះត្រង់ យុត្តិធម៌ និងមានអរិយធម៌រុងរឿង គ. សាមគ្គីភាព ភាតរភាព សេចក្តីសុខ និងសេរីភាព **លំហាត់ទី២៖** ក. វៀតណាម ខ. ថៃ គ. ចិន ឃ. ឡាវ

មេរៀនទី៣	**ប្រទេសកម្ពុជា**
រយៈពេល	១ម៉ោង
វត្ថុបំណង	ប្រាប់បានពីទីតាំងព្រំប្រទល់ប្រទេសកម្ពុជាបានត្រឹមត្រូវ ។
សម្ភារឧបទេស	ស.ស.ទំព័រ៦៤ ដល់ទំព័រ៦៥ រូបភាពផែនទីប្រទេសកម្ពុជា
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ៧
ចម្លើយនៃសំណួរ	១. ប្រទេសកម្ពុជាមានផ្ទៃដី១៨១ ០៣៥ គីឡូម៉ែត្រការេ។ ២. ប្រទេសកម្ពុជាមានព្រំប្រទល់ជាប់នឹងប្រទេសឡាវ ថៃ វៀតណាម។
ចម្លើយ/កំណែលំហាត់	**លំហាត់ទី១៖** ក. 1 ខ. 26 ក្រុង **លំហាត់ទី២៖** ក្រុងសួង ក្រុងបាវិត ក្រុងកែប...។ **លំហាត់ទី៣៖** ឈ្មោះខេត្តទាំងអស់នៅក្នុងប្រទេសកម្ពុជាមាន ខេត្តកំពត កោះកុង ព្រះសីហនុ កែប តាកែវ កំពង់ស្ពឺ កណ្តាល កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង ប៉ៃលិន បន្ទាយមានជ័យ ឧត្តរមានជ័យ ព្រះវិហារ សៀមរាប កំពង់ធំ កំពង់ចាម ត្បូងឃ្មុំ ក្រចេះ ស្ទឹងត្រែង មណ្ឌលគិរីរតនគិរី ព្រៃវែង ស្វាយរៀង។

ជំពូកទី១០

ភាពស្មោះត្រង់

រយៈពេល	២ម៉ោង
វត្ថុបំណងមេរៀន	អនុវត្តភាពស្មោះត្រង់បានខ្ជាប់ខ្ជួនបានត្រឹមត្រូវ។
ចំណងជើងមេរៀន	
មេរៀនទី១	ភាពស្មោះត្រង់របស់យើង
មេរៀនទី២	ផលវិបាកនៃភាពមិនស្មោះត្រង់

មេរៀនទី១	**ភាពស្មោះត្រង់របស់យើង**
រយៈពេល	១ម៉ោង
វត្ថុបំណង	រៀបរាប់ពីភាពស្មោះត្រង់បានត្រឹមត្រូវ។
សម្ភារៈបទេស	ស.ស. ទំព័រ៦៧ ដល់ទំព័រ៦៨ រូបភាពទំព័រទី៦៧
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ៧
ចម្លើយនៃសំណួរ	១. ខ្ញុំត្រូវមានភាពស្មោះត្រង់គ្រប់ទីកន្លែងដូចជា នៅសាលារៀន៖ ខ្ញុំមិនយករបស់មិត្តភក្តិ ឬរបស់សាលា។ នៅផ្ទះ៖ ខ្ញុំមិនលួចទ្រព្យសម្បត្តិក្នុងផ្ទះ ឬនិយាយកុហកឪពុកម្តាយ។ នៅទីសាធារណៈ៖ ខ្ញុំមិនលួចបេះបោចផ្កា ឬផ្លែឈើ និងមិនបំផ្លាញរបស់អ្នកដទៃ មិនយកសម្ភារៈអ្នកដទៃ។ ២. ភាពស្មោះត្រង់ ធ្វើឱ្យយើងមាន កេរ្តិ៍ឈ្មោះ កិត្តិយស និងសេចក្តីថ្លៃថ្នូរសម្រាប់ខ្លួនឯង គ្រួសារ និងសង្គម។ ៣. នៅកន្លែងធ្វើការមួយ គេត្រូវការបុគ្គលិកដែលមានភាពស្មោះត្រង់ ព្រោះធ្វើឱ្យការងារមានភាពរីកចម្រើន និងមានសេចក្តីសុខ។
កំណែលំហាត់	**លំហាត់ទី១៖** ក. ផ្តល់ព័ត៌មានពិតដល់អ្នកសួរ ខ. ប្រាប់ម្ចាស់របស់នៅពេលឃើញគេជ្រុះ - ផ្តល់ព័ត៌មានពិតដល់អ្នកសួរ **លំហាត់ទី២៖** ក. តើនេះជាសៀវភៅរបស់ឯងមែនឬទេ? ខ. តើមាននរណាភ្លេចបិកឬទេ?

មេរៀនទី២	**ផលវិបាកនៃភាពមិនស្មោះត្រង់**
រយៈពេល	១ម៉ោង
វត្ថុបំណង	រៀបរាប់ពីផលវិបាកនៃភាពមិនស្មោះត្រង់បានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស ទំព័រ៦៩ ដល់ទំព័រ៧០
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ៧
ចម្លើយនៃសំណួរ	១. ភាពមិនស្មោះត្រង់ជាទង្វើ ដែលសង្គមមិនទទួលស្គាល់ ហើយក៏ជាទង្វើដែលយើងត្រូវចៀសវាង។ ២. ភាពមិនស្មោះត្រង់នាំឱ្យយើងទទួលបាននូវការលំបាក ការបាត់បង់កិត្តិយស គ្មានមិត្ត និងគ្មានសេចក្តីសុខ។
កំណែលំហាត់	**លំហាត់ទី១៖** ក. ភាពមិនស្មោះត្រង់សំដៅទៅលើសកម្មភាព៖ ☑ ពេលប្រឡងលួចចម្លងឯកសារ ☑ បេះផ្កា ឬផ្លែឈើពេលម្ចាស់គេមិននៅ ☑ និយាយផ្សេង កាយវិការផ្សេង ☑ ប្តឹងទំនិញមិនគ្រប់ភ្នែកជញ្ជីង ខ. អ្នកមិនស្មោះត្រង់ជួបផលវិបាក៖ ☑ គ្មានមិត្តភក្តិ ☑ បាត់បង់កិត្តិយសនិងទ្រព្យធន ☑ ក្រុមគ្រួសារគ្មានសុភមង្គល ☑ ត្រូវគេដេញចេញពីការងារ **លំហាត់ទី២៖** (១)ទង្វើ (២)ចៀសវាង (៣)ស្មោះត្រង់ (៤)សង្គម (៥)កិត្តិយស

ជំពូកទី១១

សិទ្ធិកុមារ

រយៈពេល	២ម៉ោង
វត្ថុបំណងមេរៀន	ប្រើប្រាស់សិទ្ធិរបស់ខ្លួនបានត្រឹមត្រូវ។
ចំណងជើងមេរៀន	
មេរៀនទី១	អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ
មេរៀនទី២	សិទ្ធិកុមារ

មេរៀនទី១	**អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ**
រយៈពេល	១ម៉ោង
វត្ថុបំណង	រៀបរាប់ពីអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស. ទំព័រ៧២ ដល់ទំព័រ៧៣
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ៧
ចម្លើយនៃសំណួរ	១. អនុសញ្ញាស្តីពីសិទ្ធិកុមារបានក្លាយជាច្បាប់អន្តរជាតិ នៅថ្ងៃ០២ ខែកញ្ញា ឆ្នាំ១៩៩០។ ២. អនុសញ្ញានេះ បង្កើតឡើង ដើម្បីការពារសិទ្ធិនិងផលប្រយោជន៍របស់កុមារ។ ៣. បច្ចុប្បន្ន មានប្រទេសចំនួន 193ប្រទេស កំពុងអនុវត្តជាផ្លូវការនូវអនុសញ្ញានេះ។
កំណែលំហាត់	**លំហាត់** ១. ខ ២. ខ

មេរៀនទី២	**សិទ្ធិកុមារ**
រយៈពេល	១ម៉ោង
វត្ថុបំណង	រៀបរាប់ពីសិទ្ធិកុមារបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស ទំព័រ៧៤ ដល់ទំព័រ៧៧ រូបភាព៖ទំព័រ៧៤-៧៧
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ៧
ចម្លើយនៃសំណួរ	១. សិទ្ធិ គឺជាអ្វីៗ ដែលមនុស្សត្រូវតែមានជាចាំបាច់ ដើម្បីរស់នៅឱ្យបានសមរម្យ និងថ្លៃថ្នូរ។ សិទ្ធិមនុស្ស គឺជាអំណាចស្របច្បាប់ដែលមនុស្សមានជាស្រេចតាំងពីកំណើតមកពោល គឺមានជីវិតដែលមិនអាចដកហូតបាននិងមានសេរីភាព។ ២. កុមារមានសិទ្ធិ ៤យ៉ាង គឺសិទ្ធិរស់រានមានជីវិត សិទ្ធិក្នុងការអភិវឌ្ឍ សិទ្ធិទទួលបាន

	ការការពារ និងសិទ្ធិក្នុងការចូលរួម។ ៣. ពេលអនុវត្តសិទ្ធិ កុមារត្រូវទទួលខុសត្រូវលើសិទ្ធិរបស់ខ្លួន ដើម្បីឱ្យខ្លួនក្លាយជាកូនល្អ សិស្សល្អ មិត្តល្អ និងពលរដ្ឋល្អក្នុងសង្គម។
កំណែលំហាត់	**លំហាត់ទី១៖** គ. ដែលមានអាយុក្រោម ១៨ឆ្នាំ **លំហាត់ទី២៖** (១)មានសិទ្ធិ (២)ការអនុវត្តសិទ្ធិ (៣)ការប្រើប្រាស់ (៤)សម្បត្តិសាធារណៈ **លំហាត់ទី៣៖** ក. សិទ្ធិក្នុងការអភិវឌ្ឍ ខ. សិទ្ធិរស់រានមានជីវិត **លំហាត់ទី៤៖** សិទ្ធិរស់រានមានជីវិត ⇨ គឺត្រូវមានចំណីអាហារ ការថែទាំ មានជម្រកសមរម្យ។ សិទ្ធិក្នុងការចូលរួម ⇨ គឺផ្តល់ឱកាសឱ្យកុមារបង្កើតក្រុមកុមារ និងបញ្ចេញមតិដែលប៉ះពាល់ជីវិតរបស់ខ្លួន។ សិទ្ធិក្នុងការអភិវឌ្ឍ ⇨ គឺត្រូវឱ្យមានចំណេះដឹង បំណិន ឥរិយាបថ និងលេងកម្សាន្ត។ សិទ្ធិទទួលបានការការពារ ⇨ គឺឱ្យកុមាររួចផុតពីការរំលោភបំពានផ្លូវភេទនិងការកេងប្រវ័ញ្ចកម្លាំងពលកម្ម។

ជំពូកទី១២

ការបបួលរបស់មិត្តភក្តិ

រយៈពេល	៣ម៉ោ
វត្ថុបំណងមេរៀន	រក្សាសុវត្ថិភាពផ្ទាល់ខ្លួនបានត្រឹមត្រូវ។
ចំណងជើងមេរៀន	
មេរៀនទី១	ការបបួលប្រកបដោយប្រយោជន៍សម្រាប់កុមារ
មេរៀនទី២	ការបបួលប្រកបដោយគ្រោះថ្នាក់ដល់កុមារ
មេរៀនទី៣	វិធីការពារខ្លួន និងការឆ្លើយបដិសេធរបស់កុមារ

មេរៀនទី១	**ការបបួលប្រកបដោយប្រយោជន៍សម្រាប់កុមារ**
រយៈពេល	១ម៉ោង
វត្ថុបំណង	រៀបរាប់ពីការបបួលប្រកបដោយប្រយោជន៍សម្រាប់កុមារបានត្រឹមត្រូវ។
សម្ភារៈបង្រៀន	ស.ស.ទំព័រ៧៩ ដល់ទំព័រ៨០ រូបភាពទំព័រ៧៩
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ៧
ចម្លើយនៃសំណួរ	១. ខ្ញុំធ្លាប់បានគេបបួលដូចជា ហាត់ប្រាណ ដាំដំណាំ អានសៀវភៅ...។ ២. ការបបួលនោះមានប្រយោជន៍។ ៣. នៅពេលជួបការបបួលរបស់អ្នកណាម្នាក់ យើងត្រូវស្តាប់ពីការបបួលនោះថា តើមានប្រយោជន៍ ឬគ្មានប្រយោជន៍ បើគ្មានប្រយោជន៍ យើងត្រូវឆ្លើយបដិសេធ។
កំណែលំហាត់	**លំហាត់ទី១៖** ក. ☑ ហៅឱ្យគេធ្វើតាម ខ. ☑ មកពួកយើងទៅសាលារៀន! ☑ ឯងភ្លក់មើលទៅស្រានេះ ពិតជាមានរសជាតិឆ្ងាញ់មែន។ ☑ ទៅជាមួយខ្ញុំទៅ! **លំហាត់ទី២៖** ការបបួលមានប្រយោជន៍មានដូចជា ធ្វើលំហាត់ ទន្ទេញមេរៀន សូត្រកំណាព្យ...។

មេរៀនទី២	**ការបបួលប្រកបដោយគ្រោះថ្នាក់ដល់កុមារ**
រយៈពេល	១ម៉ោង
វត្ថុបំណង	រៀបរាប់ពីការបបួលប្រកបដោយគ្រោះថ្នាក់សម្រាប់កុមារបានត្រឹមត្រូវ ។
សម្ភារឧបទេស	ស.ស.ទំព័រ៨១ ដល់ទំព័រ៨៣ រូបភាពទំព័រ៨២
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ៧
ចម្លើយនៃសំណួរ	១. ត្រូវឆ្លើយបដិសេធ ហើយប្រញាប់រកកន្លែងសុវត្ថិភាព ២. ឆ្លើយដោយសុភាព ហើយបញ្ជាក់ពីមូលហេតុដ៏សមរម្យដូចជា សុំទោស! ខ្ញុំជាប់វេរ មិនអាចទៅបានទេ។ ៣. ចម្លើយតាមការជាក់ស្តែង
កំណែលំហាត់	**លំហាត់៖** ១. ការបបួលប្រកបដោយគ្រោះថ្នាក់មាន ខ. យើងនាំគ្នាជក់បារីសិន ទើបយើងស្រាយបញ្ហាបាន។ គ. យើងនាំគ្នាទៅលេងល្បែងស៊ីសង យើងនឹងឆាប់បានលុយចាយ។ ២. ផលវិបាក គ. មិនបានរៀនសូត្រ ង. ទទួលរងការសម្លុត ឬការវាយធ្វើបាបលើរាងកាយ ច. ត្រូវគេនាំយកទៅលក់កម្លាំងពលកម្ម ក្លាយជាជនខិលខូច ឆ. ញៀនបារី ស្រា និងគ្រឿងញៀនផ្សេងៗទៀត

មេរៀនទី៣	**វិធីការពារខ្លួន និងការឆ្លើយបដិសេធរបស់កុមារ**
រយៈពេល	១ម៉ោង
វត្ថុបំណង	រៀបរាប់ពីវិធីការពារខ្លួននិងការឆ្លើយបដិសេធរបស់កុមារបានត្រឹមត្រូវ ។
សម្ភារឧបទេស	ស.ស.ទំព័រ៨៤ ដល់ទំព័រ៨៥ រូបភាពទំព័រ៨៤
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ៧
ចម្លើយនៃសំណួរ	១. មិនត្រូវធ្វើតាម ឬទៅតាមអ្នកបបួលណាមួយដែលមិនស្គាល់ឡើយ បើស្គាល់ត្រូវពិចារណាឱ្យបានច្បាស់មុននឹងយល់ព្រម។ ២. ត្រូវឆ្លើយបដិសេធថា «ទេ» ហើយប្រញាប់គេចចេញឱ្យឆាយ រត់រកអ្នកដទៃឱ្យជួយ។
កំណែលំហាត់	**លំហាត់ទី១៖** ក. អត់ទេ! អរគុណ! ខ្ញុំមិនចេះញ៉ាំទេ។ គ. អត់ទេ! ខ្ញុំធ្លាប់ញ៉ាំហើយ។ **លំហាត់ទី២៖** (១)គ្រោះថ្នាក់ (២)បដិសេធ (៣)អន់ចិត្ត (៤)ពិចារណា

ជំពូកទី១៣

សុវត្ថិភាពរបស់កុមារនៅពេលជិះកង់

រយៈពេល	៦ម៉ោង
វត្ថុបំណងមេរៀន	ក្សាសុវត្ថិភាពរបស់ខ្លួននៅពេលជិះកង់បានត្រឹមត្រូវ។
ចំណងជើងមេរៀន	
មេរៀនទី១	ឥរិយាបថល្អនៅពេលជិះកង់តាមដងផ្លូវ
មេរៀនទី២	សារៈសំខាន់នៃការពាក់មួកសុវត្ថិភាព
មេរៀនទី៣	គ្រោះថ្នាក់ផ្សេងៗ
មេរៀនទី៤	ផលប្រយោជន៍នៃសញ្ញាចរាចរណ៍នៅតាមដងផ្លូវ
មេរៀនទី៥	សារៈសំខាន់នៃការគោរពច្បាប់ចរាចរណ៍

មេរៀនទី១	**ឥរិយាបថល្អនៅពេលជិះកង់តាមដងផ្លូវ**
រយៈពេល	២ម៉ោង
វត្ថុបំណង	ប្រើប្រាស់ឥរិយាបថល្អនៅពេលជិះកង់តាមដងផ្លូវបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស.ទំព័រ៨៧ ដល់ទំព័រ៩០ រូបភាពទំព័រ៨៧
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ៧
ចម្លើយនៃសំណួរ	១. ពេលជិះកង់តាមផ្លូវសាធារណៈត្រូវប្រកាន់ខាងស្តាំ។ ២. ដើម្បីជិះជែងគ្នាត្រូវងាកមើលឆ្វេង ស្តាំ មុខ ក្រោយ។ ៣. ពេលជិះកង់តាមដងផ្លូវ មុនពេលបត់ ត្រូវងាកមើលឆ្វេង ស្តាំ មុខ ក្រោយ ហើយលើកដៃជាសញ្ញាសុំផ្លូវដល់អ្នកនៅខាងក្រោយយើង។ ៤. ពេលធ្វើចរាចរណ៍ក្នុងរង្វង់មូល អ្នកនៅខាងឆ្វេងដៃមានអាទិភាពទៅមុន ។
កំណែលំហាត់	**លំហាត់៖** ១. ឥរិយាបថល្អនៅពេលជិះកង់គឺ៖ ក គ ច ឆ ២. ការជិះកង់ពេលយប់ ចាំបាច់ត្រូវមាន៖ ក គ យ ង

មេរៀនទី២	**សារៈសំខាន់នៃការពាក់មួកសុវត្ថិភាព**
រយៈពេល	១ម៉ោង

វត្ថុបំណង	ប្រើប្រាស់ឥរិយាបថល្អនៅពេលជិះកង់តាមដងផ្លូវបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស.ទំព័រ៩១ ដល់ទំព័រ៩២ រូបភាពទំព័រ៩១
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ៧
ចម្លើយនៃសំណួរ	១. ការពាក់មួកធម្មតាដើម្បីការពារកម្តៅ។ ២. មួកសុវត្ថិភាពមានប្រយោជន៍អាចជួយការពារក្បាលកុំឱ្យប្រេះ ឬស្រាំលលាដ៍នៅពេលមានគ្រោះថ្នាក់ចរាចរណ៍ ហើយវាក៏អាចការពារកម្តៅ និងធូលីហុយផងដែរ ។
	លំហាត់៖ ១. បំពេញល្អះ៖ (១)ធ្វើដំណើរ (២)មួកសុវត្ថិភាព (៣)ក្បាល ២. របៀបពាក់មួកសុវត្ថិភាព៖ - ជ្រើសរើសទំហំមួកសុវត្ថិភាពសមល្មមនឹងទំហំក្បាលដែលអាចការពារថ្ងាសបាន - ពាក់ឱ្យជាប់មិនរអិលចុះឡើង ឬក្រឡាប់។ - កឹបគន្លឹះខ្សែមួកក្រោមចង្កា។ - ប្រើមួកមានពណ៌ចាំង ដើម្បីឱ្យអ្នកបើកបរដទៃងាយមើលឃើញអ្នកជិះ។

មេរៀនទី៣	**គ្រោះថ្នាក់ផ្សេងៗ**
រយៈពេល	១ម៉ោង
វត្ថុបំណង	រៀបរាប់ពីគ្រោះថ្នាក់ផ្សេងៗបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស.ទំព័រ៩៣ ដល់ទំព័រ៩៤ រូបភាពទំព័រ៩៣
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ៧
ចម្លើយនៃសំណួរ	ដើម្បីកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ យើងត្រូវរៀបចំយានជំនិះរបស់យើងឱ្យបានត្រឹមត្រូវ ពោលត្រូវមានចង្កៀង វត្ថុចាំងពន្លឺ ហ្វ្រាំង ហើយមិនត្រូវជិះរលឿន និងត្រូវគោរពច្បាប់ចរាចរណ៍ទៀតផង។
កំណែលំហាត់	**លំហាត់៖** មូលហេតុដែលបណ្តាលឱ្យអ្នកជិះកង់មានគ្រោះថ្នាក់គឺ៖ ក. ជិះកង់លឿនពេក ខ. ជិះកង់ពេលយប់គ្មានភ្លើងបំភ្លឺផ្លូវ ឃ. ជិះកង់មិនគោរពច្បាប់ចរាចរណ៍ ង. រថយន្ត ម៉ូតូ បើកប៉ះ ឬបុក ឆ. ជិះកង់ពេលភ្លៀងធ្លាក់ខ្លាំងមើលផ្លូវមិនច្បាស់ ជ. សត្វពាហនៈឆ្លងកាត់ផ្លូវ។

មេរៀនទី៤	**ផលប្រយោជន៍នៃស្លាកសញ្ញាចរាចរណ៍នៅតាមដងផ្លូវ**
រយៈពេល	១ម៉ោង
វត្ថុបំណង	រៀបរាប់ពីផលប្រយោជន៍នៃស្លាកសញ្ញាចរាចរណ៍នៅតាមដងផ្លូវបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស.ទំព័រ៩៥ ដល់ទំព័រ៩៦ រូបភាព៖ ទំព័រ៩៥-៩៦
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ៧
ចម្លើយនៃសំណួរ	ដើម្បីបង្ការគ្រោះថ្នាក់នៅតាមដងផ្លូវ យើងត្រូវបើកបរដោយប្រុងប្រយ័ត្ន គោរពច្បាប់ចរាចរណ៍ និងគោរពស្លាកសញ្ញាចរាចរណ៍ឱ្យបានត្រឹមត្រូវ។
កំណែលំហាត់	**លំហាត់ទី១៖** គ. ផ្តល់ព័ត៌មានដល់អ្នកដំណើរ ឬអ្នកបើកបរ។ **លំហាត់ទី២៖** ក. ប្រយ័ត្នគ្រោះថ្នាក់ ខ. តម្រូវទៅមុខត្រង់ គ. ហាមបត់ឆ្វេង ឃ. តម្រូវបត់ស្តាំនៅខាងមុខ ង. តម្រូវបត់ឆ្វេងនៅខាងមុខ ច. តម្រូវបត់ឆ្វេង ឬស្តាំ

មេរៀនទី៥	**សារៈសំខាន់នៃការគោរពច្បាប់ចរាចរណ៍**
រយៈពេល	១ម៉ោង
វត្ថុបំណង	រៀបរាប់ពីសារសំខាន់នៃការគោរពច្បាប់ចរាចរណ៍បានត្រឹមត្រូវ ។
សម្ភារឧបទេស	ស.ស.ទំព័រ៩៧ ដល់ទំព័រ៩៨ រូបភាពទំព័រ៩៧
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ៧
ចម្លើយនៃសំណួរ	១. ពាល់ពេលធ្វើដំណើរ អ្នកធ្វើដំណើរត្រូវប្រកាន់ខាងស្តាំជាគោល។ ២. ភ្លើងសញ្ញាចរាចរណ៍ផ្តល់ប្រយោជន៍ដល់អ្នកដំណើរនិងអ្នកបើកបរឱ្យចៀសផុតពីភាពកកស្ទះ ឬគ្រោះថ្នាក់បាន។ ៣. ចំពោះអ្នកបើកបរ មិនគោរពច្បាប់ចរាចរណ៍នឹងមានផលអាក្រក់ដល់ខ្លួនដូចជា ជួបគ្រោះថ្នាក់ចរាចរណ៍ ក្លាយជាជនល្មើសច្បាប់ដែលត្រូវនគរបាលចរាចរណ៍ពិន័យ។
កំណែលំហាត់	**លំហាត់ទី១៖** ក. ផ្លូវបែកជាបួន ខ. ពេលឃើញភ្លើងពណ៌បៃតងរូបមនុស្សដើរ **លំហាត់ទី២៖** ក. ភ្លើងពណ៌ក្រហម បញ្ជាឱ្យឈប់រង់ចាំ ខ. ភ្លើងពណ៌បៃតង មានសិទ្ធិឆ្លងកាត់ ឬទៅមុខបាន គ. ភ្លើងពណ៌លឿង ប្រុងប្រយ័ត្ន

ជំពូកទី១៤

បុណ្យប្រពៃណីជាតិ

រយៈពេល	២ម៉ោង
វត្ថុបំណងមេរៀន	ប្រាប់បានពីរបៀបប្រារព្ធពិធីសំខាន់ៗនៃបុណ្យប្រពៃណីជាតិបានត្រឹមត្រូវ។
ចំណងជើងមេរៀន	
មេរៀនទី១	កាលបរិច្ឆេទ និងខ្លឹមសារសំខាន់ៗនៃបុណ្យប្រពៃណីជាតិ
មេរៀនទី២	ឥរិយាបថល្អក្នុងពេលចូលរួមពិធីបុណ្យ

មេរៀនទី១	**កាលបរិច្ឆេទ និងសារៈសំខាន់នៃបុណ្យប្រពៃណីជាតិ**
រយៈពេល	១ម៉ោង
វត្ថុបំណង	កំណត់ពីកាលបរិច្ឆេទនិងខ្លឹមសារសំខាន់ៗ នៃពិធីបុណ្យប្រពៃណីជាតិបានត្រឹមត្រូវ។
សម្ភារៈបង្រៀន	ស.ស.ទំព័រ១០០ ដល់ទំព័រ១០១
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ៧
ចម្លើយនៃសំណួរ	១. បុណ្យកឋិនទានមានរយៈពេល ២៩ថ្ងៃ ចាប់ពីថ្ងៃទី ១រោច ខែអស្សុជ រហូតដល់ថ្ងៃទី ១៥កើត ខែកក្តិក។ ២. បុណ្យមាឃបូជា គេធ្វើនៅថ្ងៃទី ១៥កើត ខែមាឃ។ បុណ្យពិសាខបូជា គេប្រារព្ធធ្វើនៅថ្ងៃទី ១៥កើត ខែពិសាខ។
កំណែលំហាត់	**លំហាត់៖** ១. គេធ្វើបុណ្យកឋិនទាន ដើម្បី គ. ប្រគេនត្រៃចីវរនិងទ័យទានផ្សេងៗទៅព្រះសង្ឃ ២. គេធ្វើបុណ្យមាឃបូជា ដើម្បី គ. រំឭកដល់ការដាក់អាយុសង្ខារបស់ព្រះពុទ្ធ ៣. គេធ្វើបុណ្យពិសាខបូជា ដើម្បី ក. រំឭកគុណដល់ពេលទាំងបីរបស់ព្រះពុទ្ធ

មេរៀនទី២	**ឥរិយាបថល្អក្នុងពេលចូលរួមពិធីបុណ្យ**
រយៈពេល	១ម៉ោង
វត្ថុបំណង	អនុវត្តនូវឥរិយាបថល្អក្នុងពេលចូលរួមពិធីបុណ្យបានត្រឹមត្រូវ។
សម្ភារៈបង្រៀន	ស.ស.ទំព័រ១០២ ដល់ទំព័រ១០៣

	រូបភាពទំព័រ១០២
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ៧
ចម្លើយនៃសំណួរ	១. ឥរិយាបថល្អក្នុងពេលចូលរួមពិធីបុណ្យផ្សេងៗ គឺយើងត្រូវរៀបចំសម្លៀកបំពាក់ឥរិយាបថឈរ អង្គុយ និងនិយាយស្តីឱ្យបានសមរម្យ។ ២. ខ្ញុំធ្លាប់បានចូលរួមក្នុងពិធីបុណ្យផ្សេងៗដូចជា បុណ្យកឋិន បុណ្យភ្ជុំបិណ្ឌ បុណ្យបច្ច័យបួនជាដើម។ បុណ្យកឋិន បុណ្យភ្ជុំបិណ្ឌ បានចូលរួមនៅវត្ត និងបុណ្យបច្ច័យបួននៅតាមផ្ទះអ្នកធ្វើមបុណ្យ។ ៣. នៅពេលបានចូលរួមពិធីបូណ្យនោះ ខ្ញុំមានអារម្មណ៍សប្បាយរីករាយប្រកបដោយទឹកចិត្តជ្រះថ្លា។
កំណែលំហាត់	**លំហាត់៖** ១. សកម្មភាពដែលត្រូវធ្វើក្នុងពិធីបុណ្យគឺ ខ. ស្លៀកសំពត់បត់ ពាក់អាវសេ គ. ជួយលើកទឹក ឬភេសជ្ជៈជូនចាស់ៗនិងភ្ញៀវ។ ២. សកម្មភាពដែលមិនត្រូវធ្វើក្នុងពិធីបុណ្យគឺ ក. បន្លំយកទ្រព្យសម្បត្តិអ្នកជវិទ ខ. ធឹកស្រាស្រវឹងនិងបង្កទំនាស់ផ្សេងៗ

ជំពូកទី១៥

តម្លៃការងារ

រយៈពេល	៣ម៉ោ
វត្ថុបំណងមេរៀន	ប្រាប់ពីតម្លៃការងារនិងផលប្រយោជន៍នៃការងារបានត្រឹមត្រូវ។
ចំណងជើងមេរៀន	
មេរៀនទី១	ការងារប្រចាំថ្ងៃរបស់ខ្ញុំ
មេរៀនទី២	ផលប្រយោជន៍នៃការធ្វើការងារ
មេរៀនទី៣	បំណិនចាំបាច់ក្នុងពេលធ្វើការងារ

មេរៀនទី១	**ការងារប្រចាំថ្ងៃរបស់ខ្ញុំ**
រយៈពេល	១ម៉ោង
វត្ថុបំណង	រៀបរាប់ពីការងារប្រចាំថ្ងៃរបស់ខ្ញុំបានត្រឹមត្រូវ។
សម្ភារៈបង្រៀន	ស.ស.ទំព័រ១០៥ ដល់ទំព័រ១០៧
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ៧
ចម្លើយនៃសំណួរ	១. កុមារធ្វើការងារផ្សេងៗជាច្រើន៖ ពេលនៅផ្ទះ : កុមារជួយការងារឪពុកម្តាយ។ ពេលនៅសាលារៀន : រៀនសូត្រ គោរពវិន័យសាលា លេងកីឡា សម្អាតថ្នាក់ និងទីធ្លាសាលា។ ក្នុងសង្គម : ចូលរួមដាំដើមឈើ ការពារបរិស្ថាន ធ្វើអនាម័យតាមទីសាធារណៈ។ ២. កុមារត្រូវខិតខំធ្វើកិច្ចការដោយគំនិតនិងកម្លាំងខ្លួនឯង ទើបមានតម្លៃជាងកិច្ចការដែលបានពីគំនិតនិងកម្លាំងអ្នកដទៃ។។
ចម្លើយ/កំណែលំហាត់	**លំហាត់ទី១៖** ក. ថែរក្សាសត្វព្រៃ គ. ប្រមូលសំរាម ង. នគរបាលចរាចរណ៍ ច. អ្នកបើកបររថយន្តឈ្នួល **លំហាត់ទី២៖** ផលវិបាកនៃការប្រកបការងារ ឬមុខរបរមិនត្រឹមត្រូវ គឺត្រូវបានគេវាយដំ ឬជាប់គុក បាក់បែកគ្រួសារ...។

មេរៀនទី២	**ផលប្រយោជន៍នៃការធ្វើការងារ**

រយៈពេល	១ម៉ោង
វត្ថុបំណង	រៀបរាប់ពីផលប្រយោជន៍នៃការធ្វើការងារបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស.ទំព័រ១០៨ ដល់ទំព័រ១១០
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ៧
ចម្លើយនៃសំណួរ	១. ការងារផ្តល់ផលប្រយោជន៍នាំឱ្យមានការអភិវឌ្ឍគំនិតប្រាជ្ញារបស់ខ្លួន មានភាពស្និទ្ធស្នាល មានសាមគ្គីភាពជាមួយគ្រួសារ មិត្តភក្តិ និងសង្គមជាតិ។ ២. ការសម្អាតបរិស្ថានតាមផ្លូវសាធារណៈ ខ្ញុំចាត់ទុកជាការងារត្រឹមត្រូវ មិនថោកទាបនោះទេ ព្រោះការងារនេះ វាមិនខុសច្បាប់ វាជាការងារជួយសង្គម វាជាករណីយកិច្ចរបស់ពលរដ្ឋម្នាក់ៗ។ ៣. ដើម្បីធ្វើការងារឱ្យបានល្អប្រសើរថែមទៀត យើងត្រូវយកចិត្តទុកដាក់រាល់ពេលបំពេញការងារ។
ចម្លើយ/កំណែលំហាត់	**លំហាត់៖** ១. ចំពោះខ្លួនឯង៖ ក. ទទួលបានបទពិសោធថ្មី ២. ចំពោះមិត្តភក្តិ៖ ក. បង្កើនមិត្ត ខ. បង្កើតភាពស្និទ្ធស្នាល គ. ផ្តល់ភាពអនុគ្រោះ ៣. ចំពោះគ្រួសារនិងសង្គម៖ ខ. មានទំនាក់ទំនងល្អ គ. មានសុភមង្គល ង. មានការគោរពច្បាប់ ច. មានសេចក្តីសុខ សុវត្ថិភាព

មេរៀនទី៣	**បំណិនចាំបាច់ក្នុងពេលធ្វើការងារ**
រយៈពេល	១ម៉ោង
វត្ថុបំណង	ប្រើប្រាស់បំណិនចាំបាច់ក្នុងពេលធ្វើការងារបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស.ទំព័រ១១១ ដល់ទំព័រ១១២
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ៧
ចម្លើយនៃសំណួរ	១. ដើម្បីឱ្យការងារទទួលបានជោគជ័យ យើងត្រូវមានចំណុចសំខាន់ៗ ដូចខាងក្រោម៖ - ត្រូវជ្រើសរើសការងារទៅតាមសមត្ថភាពរបស់ខ្លួន - ព្យាយាមធ្វើកិច្ចការដោយយកចិត្តទុកដាក់ - មិនរាថយនឹងកិច្ចការលំបាក គឺធ្វើការងារដោយសេចក្តីអត់ធ្មត់ឱ្យអស់លទ្ធភាព។ ២. ត្រូវជ្រើសរើសការងារទៅតាមសមត្ថភាព ព្រោះដើម្បីឱ្យការងារទទួលបានជោគជ័យ។ ៣. បើខ្វះភាពអំណត់ព្យាយាម យើងមិនអាចធ្វើការងារមួយទទួលបានជោគជ័យនោះទេ ព្រោះការងារនោះធ្វើមិនបានសម្រេច។

ជំពូកទី១៦

អំណាចនីតិប្រតិបត្តិ

រយៈពេល	៤ម៉ោង
វត្ថុបំណងមេរៀន	ប្រាប់បានពីអំណាចនីតិប្រតិបត្តិបានត្រឹមត្រូវ។
ចំណងជើងមេរៀន	
មេរៀនទី១	រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
មេរៀនទី២	ក្រសួងនានា

មេរៀនទី១	**រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា**
រយៈពេល	៣ម៉ោង
វត្ថុបំណង	រៀបរាប់ពីការបង្កើតរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានត្រឹមត្រូវ។
សម្ភារៈបង្រៀន	ស.ស.ទំព័រ១១៤ ដល់ទំព័រ១១៧ រូបភាពទំព័រ១១៤
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ៧
ចម្លើយនៃសំណួរ	១. ការបង្កើតរដ្ឋាភិបាលមានដំណើរការដូចតទៅ៖ ព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូប នៃគណៈបក្សដែលឈ្នះឆ្នោតឱ្យបង្កើតរដ្ឋាភិបាល។ វរជនដែលត្រូវបានចាត់តាំងនោះនាំសហការីដែលជាតំណាងរាស្ត្រទៅសុំសេចក្តីទុកចិត្តពីរដ្ឋសភា។ កាលបើរដ្ឋសភាបានបោះឆ្នោតទុកចិត្តហើយនោះ ព្រះមហាក្សត្រចេញព្រះរាជក្រឹត្យតែងតាំងគណៈរដ្ឋមន្ត្រី។ ២. គណៈរដ្ឋមន្ត្រីជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។ ៣. គណៈរដ្ឋមន្ត្រីត្រូវបានដឹកនាំដោយនាយករដ្ឋមន្ត្រី។ ៤. គណៈរដ្ឋមន្ត្រីធ្វើការងារដូចជា៖ - ប្រជុំរាល់សប្តាហ៍នៅទីស្តីការគណៈរដ្ឋមន្ត្រី - អង្គប្រជុំនោះត្រូវដឹកនាំដោយនាយករដ្ឋមន្ត្រី ហើយនាយករដ្ឋមន្ត្រីអាចប្រគល់ភារកិច្ចជូនឧបនាយករដ្ឋមន្ត្រី ដឹកនាំអង្គប្រជុំពិនិត្យស្រាវជ្រាវបាន។ - ធ្វើកំណត់ហេតុនិងត្រូវយកកំណត់ហេតុនោះ ថ្វាយព្រះមហាក្សត្រទ្រង់ជ្រាប។ ៥. រាជរដ្ឋាភិបាលមានតួនាទីនិងភារកិច្ចដូចជា៖ - ដឹកនាំកិច្ចការងារនយោបាយនិងការងារសាធារណៈរបស់ប្រទេសជាតិ - ទទួលបន្ទុកអនុវត្តច្បាប់ដែលអនុម័តដោយរដ្ឋសភានិងធ្វើសំណើតែងតាំងអភិបាលរាជធានី.ខេត្ត ក្រុង.ស្រុក.ខណ្ឌ

	- រៀបចំសេចក្តីព្រាងច្បាប់នានា ដើម្បីដាក់ជូនរដ្ឋសភាពិនិត្យសម្រេច។
ចម្លើយ/កំណែលំហាត់	**លំហាត់ទី១៖** ក. អំណាចនីតិប្រតិបត្តិ ខ. រាល់សប្តាហ៍ គ. ទីស្តីការគណៈរដ្ឋមន្ត្រី **លំហាត់ទី២៖** ក. រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា ⇨ ជាអ្នកដឹកនាំនិងកសាងប្រទេសឱ្យរីកចម្រើន។ ខ. ព្រះមហាក្សត្រ ⇨ ចេញព្រះរាជក្រឹត្យតែងតាំងគណៈរដ្ឋមន្ត្រី។ គ. គណៈរដ្ឋមន្ត្រី ⇨ ធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែងផ្សេងៗ **លំហាត់ទី៣៖** សមាសភាពសមាជិករាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាមាន៖ នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ។

មេរៀនទី២	**ក្រសួងនានា**
រយៈពេល	១ម៉ោង
វត្ថុបំណង	រៀបរាប់ពីក្រសួងនានាដែលជាស្ថាប័នចំណុះរបស់រាជរដ្ឋាភិបាលបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស.ទំព័រ១១៨ ដល់ទំព័រ១១៩
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ៧
ចម្លើយនៃសំណួរ	១. រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាមានក្រសួងចំនួន 28 ក្រសួងគឺ ក្រសួងព្រះបរមរាជវាំង ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភានិងអធិការកិច្ច ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងព័ត៌មាន ក្រសួងសុខាភិបាល ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្រសួងរ៉ែនិងថាមពល ក្រសួងផែនការ ក្រសួងពាណិជ្ជកម្ម ក្រសួងអប់រំ យុវជននិងកីឡា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រសួងបរិស្ថាន ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងប្រៃណីយ៍និងទូរគមនាគមន៍ ក្រសួងធម្មការនិងកិច្ចការសាសនា ក្រសួងកិច្ចការនារី ក្រសួងសាធារណៈការនិងដឹកជញ្ជូន ក្រសួងយុត្តិធម៌ ក្រសួងទេសចរណ៍ ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ ក្រសួងធនធានទឹកនិងឧតុនិយម ក្រសួងការងារនិងបណ្តុះ បណ្តាលវិជ្ជាជីវៈ ក្រសួងមុខងារសាធារណៈ។ ២. រដ្ឋមន្ត្រីក្រសួង អប់រំ យុវជន និងកីឡា បច្ចុប្បន្នឈ្មោះ លោក ហង់ ជួន ណារ៉ុន។
ចម្លើយ/កំណែលំហាត់	**លំហាត់៖** ក. ចៅក្រម ⇨ ក្រសួងយុត្តិធម៌ ខ. វេជ្ជបណ្ឌិត ⇨ ក្រសួងសុខាភិបាល គ. គ្រូបង្រៀន⇨ ក្រសួងអប់រំ យុវជន និងកីឡា ឃ. នគរបាល ⇨ ក្រសួងមហាផ្ទៃ

ជំពូកទី១៧

អាជ្ញាធរដែនដី

រយៈពេល	៤ម៉ោង
វត្ថុបំណងមេរៀន	ប្រាប់ពីការកិច្ចរបស់អាជ្ញាធរដែនដីបានត្រឹមត្រូវ។
ចំណងជើងមេរៀន	
មេរៀនទី១	អាជ្ញាធរដែនដីរាជធានី.ខេត្ត
មេរៀនទី២	អាជ្ញាធរក្រុង.ស្រុក.ខណ្ឌ
មេរៀនទី៣	អាជ្ញាធរឃុំ.សង្កាត់
មេរៀនទី៤	មេភូមិ

មេរៀនទី១	**អាជ្ញាធរដែនដីរាជធានី.ខេត្ត**
រយៈពេល	១ម៉ោង
វត្ថុបំណង	រៀបរាប់ពីអាជ្ញាធរដែនដី រាជធានី.ខេត្តបានត្រឹមត្រូវ។
សម្ភារៈបង្រៀន	ស.ស.ទំព័រ១២១ ដល់ទំព័រ១២២
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ៧
ចម្លើយនៃសំណួរ	១. អាជ្ញាធររាជធានី.ខេត្ត ជាអ្នកតំណាងរដ្ឋអំណាចកណ្តាល ជាអ្នកគ្រប់គ្រងដែនដីតាមខណ្ឌសីមារបស់រាជធានី.ខេត្ត ដែលមានក្រុង.ស្រុក.ខណ្ឌ ឃុំ.សង្កាត់ ដើម្បីអភិវឌ្ឍនិងសម្រេចឱ្យបានតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ២. អាជ្ញាធរដែនដីមានការកិច្ច៖ - ការពារសិទ្ធសេរីភាពរបស់ប្រជាពលរដ្ឋ - ធ្វើផែនការកម្មវិធីអភិវឌ្ឍ - កែលម្អជីវភាពប្រជាជន - រៀបចំកែទម្រង់ដីធ្លី - ទទួលព័ត៌មានពីអាជ្ញាធរក្រុង.ស្រុក.ខណ្ឌ - ផ្តល់របាយការណ៍ទៅក្រសួងមហាផ្ទៃពីលទ្ធផលការងារ។ ៣. ការងារប្រចាំថ្ងៃរបស់អាជ្ញាធររាជធានី.ខេត្តមាន៖ - រៀបចំគម្រោងចរិកាប្រចាំឆ្នាំ - បែងចែកនិងដាក់ផែនការការងារដល់ក្រុង.ស្រុក.ខណ្ឌ - ការពារថែរក្សាសម្បត្តិសាធារណៈ វប្បធម៌ជាតិ បេតិកភណ្ឌជាតិ និងសណ្តាប់ធ្នាប់

	សាធារណៈ - ត្រួតពិនិត្យការងារតាម ក្រុង.ស្រុក.ខណ្ឌ សរុបលទ្ធផលការងារ និងធ្វើរបាយការណ៍ទៅក្រសួងមហាផ្ទៃ។
ចម្លើយ/កំណែលំហាត់	**លំហាត់៖** ១. អាជ្ញាធររាជធានី.ខេត្ត ផ្តល់របាយការណ៍ជាប្រចាំទៅ៖ គ. ក្រសួងមហាផ្ទៃ ២. អាជ្ញាធររាជធានី.ខេត្ត ធ្វើការដើម្បីអភិវឌ្ឍនិងសម្រេចតាមគោលនយោបាយរបស់៖ គ. រាជរដ្ឋាភិបាល

មេរៀនទី២	**អាជ្ញាធរក្រុង.ស្រុក.ខណ្ឌ**
រយៈពេល	១ម៉ោង
វត្ថុបំណង	រៀបរាប់ពីអាជ្ញាធរក្រុង.ស្រុក.ខណ្ឌបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស.ទំព័រ១២៣ ដល់ទំព័រ១២៤
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ៧
ចម្លើយនៃសំណួរ	១. អាជ្ញាធរក្រុង.ស្រុក.ខណ្ឌមានមុខងារនិងភារកិច្ច៖ - រៀបចំកែទម្រង់ដីធ្លី កែលម្អភូមិឋានឱ្យបានល្អនិងមានការអភិវឌ្ឍ។ - រក្សាទំនៀមទម្លាប់ប្រពៃណី - ស្តារនិងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ - ផ្សព្វផ្សាយនិងអនុវត្តច្បាប់ ឬបទបញ្ជា ព្រមទាំងជំរុញគ្រប់សកម្មភាពដែលត្រូវអនុវត្ត។ - តាមដានសកម្មភាពការងារនិងទទួលព័ត៌មាន ឬរបាយការណ៍ពីអាជ្ញាធរឃុំ.សង្កាត់។ - ផ្តល់របាយការណ៍លទ្ធផលការងារដែលសម្រេចបានជូនអាជ្ញាធររាជធានី.ខេត្ត។ ២. អាជ្ញាធរក្រុង.ស្រុក.ខណ្ឌ មានការងារប្រចាំថ្ងៃ៖ - រៀបចំបញ្ជីប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោត។ - ចម្លងនិងរក្សាបញ្ជីអត្រានុកូលដ្ឋាន។ - ដំរឿននិងចុះបញ្ជីស្ថិតិប្រជាពលរដ្ឋ។ - ដាក់ផែនការឱ្យឃុំ.សង្កាត់អនុវត្ត។ - ត្រួតពិនិត្យនិងសម្របសម្រួលការងារតាមអាជ្ញាធរឃុំ.សង្កាត់។ - ធ្វើរបាយការណ៍ជូនរាជធានី.ខេត្ត។
ចម្លើយ/កំណែលំហាត់	**លំហាត់ទី១៖** ក. រាជធានី.ខេត្ត **លំហាត់ទី២៖** ខ. ឃុំ.សង្កាត់

មេរៀនទី៣	**អាជ្ញាធរឃុំ.សង្កាត់**
រយៈពេល	១ម៉ោង
វត្ថុបំណង	រៀបរាប់ពីមុខងារអាជ្ញាធរឃុំ.សង្កាត់បានត្រឹមត្រូវ។

សម្ភារឧបទេស	ស.ស.ទំព័រ១២៥ ដល់ទំព័រ១២៦
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ៧
ចម្លើយនៃសំណួរ	១. ពេលមានបញ្ហាក្នុងគ្រួសារ យើងត្រូវទៅទំនាក់ទំនងអាជ្ញាធរឃុំ.សង្កាត់។ ២. អ្នកការពារសណ្តាប់ធ្នាប់សាធារណៈសន្តិសុខសង្គម គឺអាជ្ញាធរឃុំ.សង្កាត់។ ៣. អាជ្ញាធរឃុំ.សង្កាត់ត្រូវធ្វើរបាយការណ៍ជូនទៅ ក្រុង.ស្រុក.ខណ្ឌ។ ៤. ចម្លើយតាមការយល់ដឹងរបស់សិស្ស។
ចម្លើយ/កំណែលំហាត់	**លំហាត់៖** ១. ការងារប្រចាំថ្ងៃរបស់អាជ្ញាធរឃុំ.សង្កាត់គឺ៖ ក. រក្សាការពារសណ្តាប់ធ្នាប់សាធារណៈសន្តិសុខសង្គមជូនប្រជាពលរដ្ឋ។ ២. ការចុះបញ្ជីអត្រានុកូលដ្ឋានធ្វើនៅ៖ គ. សាលាឃុំ.សង្កាត់ ៣. អាជ្ញាធរឃុំ.សង្កាត់ធ្វើរបាយការណ៍ជូន៖ ក. ក្រុង.ស្រុក.ខណ្ឌ

មេរៀនទី៤	**មេភូមិ**
រយៈពេល	១ម៉ោង
វត្ថុបំណង	កំណត់និយមន័យភូមិនិងប្រាប់តួនាទីភារកិច្ចរបស់មេភូមិបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស.ទំព័រ១២៧ ដល់ទំព័រ១២៨
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ៧
ចម្លើយនៃសំណួរ	១. ផ្ទះច្រើនខ្នងផ្តុំរួមគ្នាបង្កើតបានជាភូមិ។ ២. ក្នុងភូមិនីមួយៗមានមេភូមិម្នាក់ជាអ្នកដឹកនាំ។ ៣. មេភូមិមានភារកិច្ចរក្សារបៀបរៀបរយក្នុងភូមិ បញ្ជូនព័ត៌មានសំខាន់ៗ ទៅមេឃុំនិងនាំព័ត៌មានពីមេឃុំទៅឱ្យប្រជាជនវិញ។
ចម្លើយ/កំណែលំហាត់	**លំហាត់៖** (១)ផ្តុំរួមគ្នា (២)ឈ្មោះ (៣)តូច (៤)ចំនួន (៥)ពានដី (៦)ផ្លូវ (៧)មេភូមិ (៨)ប្រជារាស្ត្រ (៩)ទទួលខុសត្រូវ។

ជំពូកទី១៨

ការប្រើប្រាស់ដីនៅតាមតំបន់នានា

រយៈពេល	៥ម៉ោង
វត្ថុបំណងមេរៀន	ប្រាប់បានពីការប្រើប្រាស់ដីនៅតាមតំបន់នានាបានត្រឹមត្រូវ។
ចំណងជើងមេរៀន	
មេរៀនទី១	ដីនៅតំបន់បឹងទន្លេសាប
មេរៀនទី២	ដីដំណាំបន្ទាប់បន្សំ
មេរៀនទី៣	ដីដំណាំឧស្សាហកម្ម
មេរៀនទី៤	គួរចម្លងផែនទីប្រទេសកម្ពុជា

មេរៀនទី១	**ដីនៅតំបន់បឹងទន្លេសាប**
រយៈពេល	១ម៉ោង
វត្ថុបំណង	ប្រើប្រាស់ដីតំបន់បឹងទន្លេសាបបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស.ទំព័រ១៣០ ដល់ទំព័រ១៣១
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ៧
ចម្លើយនៃសំណួរ	១. ដីនៅជុំវិញបឹងទន្លេសាប មានលក្ខណៈជាដីសម្បូរល្បាប់ មានដីជាតិ មានទឹកគ្រប់គ្រាន់។ ២. ខេត្តដែលនៅជុំវិញបឹងទន្លេសាបមានខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តសៀមរាប និងខេត្តកំពង់ធំ។ ៣. ការធ្វើស្រែនៅជុំវិញបឹងទន្លេសាបបានផលច្រើន ព្រោះដីនៅទីនោះ ជាដីទំនាបលិចទឹកនៅរដូវវស្សា និងជាដីល្បាប់សម្បូរដីជាតិ ជាតំបន់ដីសើម។
ចម្លើយ/កំណែលំហាត់	**លំហាត់ទី១៖** ដីល្បាប់មាននៅ៖ ក. តំបន់បឹងទន្លេសាប **លំហាត់ទី២៖** គេធ្វើស្រែនិងចម្ការបានផលច្រើនលើដីល្បាប់

មេរៀនទី២	**ដីដំណាំបន្ទាប់បន្សំ**
រយៈពេល	១ម៉ោង
វត្ថុបំណង	រៀបរាប់ពីដំណាំបន្ទាប់បន្សំបានត្រឹមត្រូវ។

សម្ភារឧបទេស	ស.ស.ទំព័រ១៣២ ដល់ទំព័រ១៣៣ រូបភាពទំព័រ១៣២
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ៧
ចម្លើយនៃសំណួរ	១. ប្រភេទដីមានដីជាតិខ្ពស់ គឺដីក្រហមនិងដីល្បាប់។ ២. គេអាចដាំដំណាំបន្ទាប់បន្សំនៅលើដីមមោក ដីល្បាប់ ដីក្រហម។ ៣. ដំណាំបន្ទាប់បន្សំមាន ចេក ល្ពៅ ត្រាវ ដំឡូង ត្រប់...។
ចម្លើយ/កំណែលំហាត់	**លំហាត់៖** ប្រជាជនកម្ពុជាភាគច្រើនមានមុខរបរជា៖ ក. កសិករ

មេរៀនទី៣	**ដីដំណាំឧស្សាហកម្ម**
រយៈពេល	១ម៉ោង
វត្ថុបំណង	រៀបរាប់ពីដំណាំឧស្សាហកម្មបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស.ទំព័រ១៣៤ ដល់ទំព័រ១៣៥
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ៧
ចម្លើយនៃសំណួរ	១. គេដាំដំណាំឧស្សាហកម្មនៅតំបន់ទំនាប និងដីតាមបណ្តោយសងខាងទន្លេសាប ទន្លេមេគង្គ ទន្លេបាសាក់ និងតំបន់ខ្ពង់រាប។ ២. ដំណាំឧស្សាហកម្មមាន ពោត សណ្តែក ការ្ហៅ ក្រចៅ កប្បាស កៅស៊ូ...។ ៣. ដំណាំឧស្សាហកម្មចម្បងជាងគេគឺ កប្បាស កៅស៊ូ។
	លំហាត់ទី១៖ ដើម្បីដាំដំណាំឱ្យបានទិន្នផលខ្ពស់ ប្រជាកសិករត្រូវ៖ ក. ជ្រើសរើសពូជ គ. ជ្រើសរើសដី **លំហាត់ទី២៖** (១)ឧស្សាហកម្ម (២)ខ្ពង់រាប (៣)ដីក្រហម (៤)សម្បកកង់

មេរៀនទី៤	**គូរចម្លងផែនទីប្រទេសកម្ពុជា**
រយៈពេល	២ម៉ោង
វត្ថុបំណង	គូរគំនូរចម្លងផែនទីប្រទេសកម្ពុជាបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស.ទំព័រ១៣៦ ដល់ទំព័រ១៣៧
ដំណើរការបង្រៀន	**វគ្គទី១ :** គូរក្រឡាលើរូបដើម លោកគ្រូ អ្នកគ្រូត្រូវធ្វើត្រៀមទុកឱ្យហើយមុនយកបង្ហាញសិស្ស។ - នៅលើរូបផែនទីមួយ គូរក្រឡាការេ យកទំហំក្រឡាមួយៗ ស្មើៗគ្នា ហើយដាក់លេខរៀងនៅជួរដេក និងដាក់អក្សររៀងនៅជួរឈរ ក្នុងចន្លោះការេនីមួយៗ។ - គូរបន្ទាត់ទ្រេតឆ្វេងពីរ

	- គូរបន្ទាត់ទ្រេតស្តាំបី **វគ្គទី២** : គូរក្រឡាលើក្តារខៀន - គូរក្រឡាការនៅក្តារខៀនឱ្យស្មើគ្នានឹងចំនួនក្រឡានៅរូបដើម តែទំហំក្រឡាការទាំងអស់នោះ ត្រូវពង្រីកឱ្យធំជាងរូបដើម ដើម្បីឱ្យសិស្សមើលឃើញច្បាស់។ - ចុះលេខរៀង និងអក្សររៀងនៅតាមចន្លោះការនីមួយៗ ឱ្យដូចរូបដើម - គូរបន្ទាត់ទ្រេតឆ្វេងពីរ បន្ទាត់ទ្រេតស្តាំបី។ **វគ្គទី៣** : គូរព្រំប្រទល់ប្រទេស **វគ្គទី៤** : គូរខ្សែទន្លេទាំងបួន
ចម្លើយនៃសំណួរ	១. ដើម្បីគូរចម្លងផែនទីឱ្យបានត្រឹមត្រូវ យើងត្រូវគូរក្រឡាការ ហើយចុះលេខរៀងនៅជួរដេក និងដាក់អក្សររៀងនៅជួរឈរ នៃខ្សែក្រឡានីមួយៗ។ បន្ទាប់មក យើងចាប់ផ្តើមគូរចម្លងរូបផែនទីថ្មី ដោយពិនិត្យនិងគូរតាមរូបដើម។ ២. ដើម្បីបានផែនទីតូច ឬធំជាងរូបដើម យើងត្រូវបង្រួម ឬពង្រីកក្រឡាតាមការចង់បាន។
ចម្លើយ/កំណែលំហាត់	**លំហាត់៖** ចម្លើយតាមការដាក់ស្តែង

ជំពូកទី១៩

ជីវភាពសម័យបុរាណ

រយៈពេល	៤ម៉ោង
វត្ថុបំណងមេរៀន	ប្រាប់បានពីជីវភាពនាសម័យបុរាណបានត្រឹមត្រូវ។
ចំណងជើងមេរៀន	
មេរៀនទី១	បុរេប្រវត្តិនៃប្រទេសកម្ពុជា
មេរៀនទី២	សម័យនគរភ្នំ

មេរៀនទី១	**បុរេប្រវត្តិនៃប្រទេសកម្ពុជា**
រយៈពេល	២ម៉ោង
វត្ថុបំណង	រៀបរាប់ពីបុរេប្រវត្តិបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស.ទំព័រ១៣៩ ដល់ទំព័រ១៤១ រូបភាព៖ ទំព័រ១៣៩-១៤០
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ៧
ចម្លើយនៃសំណួរ	១. គេដឹងពីសម័យបុរេប្រវត្តិដោយសារ ការស្រាវជ្រាវលើគ្រោងឆ្អឹងមនុស្ស ឧបករណ៍ប្រើប្រាស់ និងកម្ទេចសំណល់ផ្សេងៗដែលបានបន្សល់ទុក។ ២. ស្ថានីយបុរេប្រវត្តិមានទីតាំងនៅកន្លែង ស្ថានីយម្លូព្រៃ ស្ថានីយល្អាងស្ពាន ស្ថានីយព្រែកឆ្លូង ស្ថានីយសំរោងសែននិងអន្លង់ផ្តៅ ស្ថានីយភ្នំក្បាលរមាសក្នុងខេត្តកំពត និងស្ថានីយព្រះនេត្រព្រះ ក្នុងខេត្តបន្ទាយមានជ័យ។ ៣. មនុស្សសម័យបុរេប្រវត្តិច្រើនរស់នៅជាក្រុមៗតាមរូងភ្នំ។ ៤. មនុស្សសម័យបុរេប្រវត្តិប្រកបរបរចិញ្ចឹមជីវិតដោយ នេសាទត្រី បរបាញ់សត្វ និងបេះផ្លែឈើជាអាហារ។ ៥. ពួកគេមានជំនឿលើខ្មោច អារក្ស និងអ្នកតា។
ចម្លើយ/កំណែលំហាត់	**លំហាត់៖** ១. មនុស្សសម័យបុរេប្រវត្តិយក ខ. រូងភ្នំជាជម្រក គ. ផ្ទះជាជម្រក ២. មនុស្សសម័យបុរេប្រវត្តិប្រកបមុខរបរ ខ. បរបាញ់សត្វ គ. នេសាទត្រី ង. បេះផ្លែឈើ

មេរៀនទី២	**សម័យនគរភ្នំ**
រយៈពេល	២ម៉ោង
វត្ថុបំណង	រៀបរាប់ពីសម័យនគរភ្នំបានត្រឹមត្រូវ។
សម្ភារឧបទេស	ស.ស.ទំព័រ១៤២ ដល់ទំព័រ១៤៥ រូបភាពទំព័រ១៤៣
ដំណើរការបង្រៀន	មើលលំនាំបង្រៀនទំព័រ៧
ចម្លើយនៃសំណួរ	១. សម័យនគរភ្នំស្ថិតនៅក្នុងសតវត្សទី១ រហូតដល់សតវត្សទី ៦។ ២. ទីក្រុងនៃសម័យនគរភ្នំឈ្មោះ នរៈវរៈនគរ។ ៣. មនុស្សសម័យនគរភ្នំរស់នៅប្រមូលផ្តុំគ្នាជាភូមិ តំបន់ចាប់ពី 50ដល់ 60 គ្រួសារឡើងទៅ។ ពួកគេសង់ផ្ទះខ្ពស់ពីដី ធ្វើអំពីឈើប្រក់ស្លឹក។ ពួកគេប្រកបរបរកសិកម្មនិងធ្វើពាណិជ្ជកម្ម។ ៤. ប្រជារាស្ត្រមានជំនឿលើព្រហ្មញ្ញសាសនានិងព្រះពុទ្ធសាសនា។
ចម្លើយ/កំណែលំហាត់	**លំហាត់ទី១៖** ក. ព្រះបាទហ៊ុនទៀន ខ. ស្រុកអង្គរបុរី ខេត្តតាកែវ គ. ទេវតា **លំហាត់ទី២៖** ក. នគរភ្នំមានទីក្រុងឈ្មោះថា ⇨ នរៈវរៈនគរ បច្ចុប្បន្នស្ថិតនៅក្នុងស្រុកអង្គរបុរី ខេត្តតាកែវ។ ខ. សម័យនគរភ្នំស្ថិតនៅក្នុង ⇨ សតវត្សទី១ ដល់សតវត្សទី៦ នៃគ្រឹស្តសករាជ។ គ. ប្រជារាស្ត្រជឿជាក់លើ ⇨ ព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនា។ **លំហាត់ទី៣៖** ព្រះបាទហ៊ុនទៀននិងព្រះនាងលីវយី ទ្រង់បានឡើងសោយរាជ្យនៅសម័យនគរភ្នំ ដែលបច្ចុប្បន្នស្ថិតនៅក្នុងស្រុកអង្គរបុរី ខេត្តតាកែវ។ នៅសម័យនគរភ្នំ មនុស្សមានការអភិវឌ្ឍច្រើន ពួកគេចេះប្រកបរបរកសិកម្ម និងពាណិជ្ជកម្មយ៉ាងច្បាស់លាស់។ នៅសម័យនោះ ប្រជារាស្ត្រជឿជាក់លើព្រហ្មញ្ញសាសនានិងព្រះពុទ្ធសាសនា។

ក្រសួងអប់រំ យុវជន និងកីឡា

និង

អង្គការដើម្បីភាពញញឹមនៃកុមារ





សូមថ្លែងអំណរគុណ

ចំពោះអ្នកខ្ចប់ត្តម្ភថវិកាដល់ដំណើរការគម្រោងចងក្រង និងបោះពុម្ពស្បៀវភៅពន្លឿនការសិក្សាដូចជា ៖













រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

មាត្រា៦៥៖ រដ្ឋត្រូវការពារ និងលើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋ ក្នុងការអប់រំប្រកបដោយគុណភាពនៅគ្រប់កម្រិត និងត្រូវចាត់វិធានការគ្រប់បែបយ៉ាងជាដំហានៗ ដើម្បីឱ្យការអប់រំនេះបានទៅដល់ប្រជាពលរដ្ឋគ្រប់រូប។ រដ្ឋយកចិត្តទុកដាក់លើវិស័យអប់រំកាយនិងកីឡាដែលជាសុខុមាលភាពរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប។

មាត្រា៦៦៖ រដ្ឋកសាងប្រព័ន្ធអប់រំមួយពេញលេញ និងឯកភាពនៅទូទាំងប្រទេសដែលធានាឱ្យបាននូវគោលការណ៍សេរីភាពខាងសិក្សាធិការ និងគោលការណ៍សមភាពក្នុងការអប់រំ ដើម្បីឱ្យប្រជាពលរដ្ឋគ្រប់រូបមានភ័ព្វសំណាងគ្រប់គ្រាន់ស្មើគ្នាក្នុងការកសាងជីវិត។

មាត្រា៦៧៖ រដ្ឋអនុវត្តកម្មវិធីសិក្សានិងគោលការណ៍គរុកោសល្យទំនើបរាប់បញ្ចូលទាំងបច្ចេកវិទ្យានិងភាសាបរទេស។ រដ្ឋគ្រប់គ្រងគ្រឹះស្ថានសិក្សានិងថ្នាក់សិក្សាសាធារណៈនិងឯកជននៅគ្រប់ភូមិសិក្សា។

មាត្រា៦៨៖ រដ្ឋផ្តល់កិច្ចការអប់រំផ្នែកបឋម និងមធ្យមសិក្សានៅសាលារៀនសាធារណៈសម្រាប់ប្រជាពលរដ្ឋគ្រប់រូបដោយឥតមានបង់ថ្លៃយ៉ាងតិច ៩ឆ្នាំ។

ច្បាប់ស្តីពីការអប់រំនៃព្រះរាជាណាចក្រកម្ពុជា

មាត្រា៣១៖ ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិទទួលបានការអប់រំយ៉ាងតិច៩(ប្រាំបួន)ឆ្នាំប្រកបដោយគុណភាពដោយឥតបង់ថ្លៃនៅសាលារៀនសាធារណៈ។ ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវរៀបចំគោលនយោបាយផែនការយុទ្ធសាស្ត្រ និងវិធានការជាដំហានៗ ដើម្បីធានាឱ្យប្រជាពលរដ្ឋគ្រប់រូបទទួលបានការអប់រំប្រកបដោយគុណភាព ស្របតាមបទបញ្ញត្តិដែលមានចែងក្នុងច្បាប់នេះ។

ការអប់រំសម្រាប់ទាំងអស់គ្នា!

ទាំងអស់គ្នាសម្រាប់ការអប់រំ!